ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Apr-2015, 14:20
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៨:០៤នាទី**

**សវនាការលើកទី២៦៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក រ៉ូជឺ ហ្វីលីព | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ថូដ ឡូវែល (ជំនួយការមេធាវី) | អង់គ្លេស |
| លោក ចេសិន បារ៉ែត (មេធាវីរបស់សាក្សី) | អង់គ្លេស |
| លោក រីឆាដ ឌុដម៉ាន (2-TCW-923) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រីឆាដ ខុដម៉ាន** (2-TCW-923)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ទំព័រ ៤
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.......................................................................ទំព័រ ៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:០៤:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី រីឆាដ ឌុដម៉ាន *(Richard Dudman)* តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក រីឆាដ ឌុដម៉ាន *(Richard Dudman)* តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនង ញាតិលោហិត ឬញាតិពន្ធ ជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មនេះផងដែរ គឺមានលោក ថូដ ឡូវែល *(Todd Lowell)* ដែលជាជំនួយការមេធាវី និង ចេសិន បារ៉ែត *(Jason Barrett)* ជាមេធាវី របស់សាក្សី។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេក ទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះ បានរៀបចំរួចរាល់អស់ហើយ។ រីឯសាក្សីបានត្រៀមខ្លួន រួចជាសម្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ កញ្ញា ជា ស៊ីវហ៉ង។

បាទ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី៣១ -- នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលាលើរូបខ្លួនឡើយ។

[០៨:០៧:១៨]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នួន ជា នៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះ វុំវ៉ៃ វិលមុខ មិនអាចអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបសួរលោក ថូដ ឡូវែល!

**លោក ថូដ ឡូវែល៖**

ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក វីឆាត ឌុដម៉ាន ពិតមែនទេ?

**លោក វីឆាដ ឌុដម៉ាន៖**

លោកប្រធាន ខ្ញុំអត់យល់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមសួរទៅលោក ថូដៗ ឡូវែល ជាមុន ដើម្បីជម្រាបជូនសាធារណជនជ្រាបអំពីវត្តមានរបស់ជំនួយការមេធាវី ហើយនិងមេធាវីរបស់លោក ដែលនៅអង្គុយអមលោក វីឆាដ ឌុដម៉ាន ជាមុនសិន ដើម្បីឲ្យយល់អំពីហេតុអីបានជាមានវត្តមានលោក ថូដ ឡូវែល ហើយនិងលោក ចូសាន់ បារ៉ែត។

[០៨:១០:១៨]

**លោក ថូដ ឡូវែល៖**

អរុណសួស្តី ខ្ញុំឈ្មោះ ថូដ ឡូ។ ខ្ញុំជាមេធាវីដែលធ្វើការនៅក្រសួងយុត្តិធម៌នៃសហរដ្ឋអាមេរិកសម្រាប់ទីក្រុងមេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយៗ ហើយចុះលោកម្នាក់ទៀត លោកឈ្មោះអី?

**លោក ចូសាន់ បារ៉ែត៖**

ខ្ញុំឈ្មោះ ចេសិន បារ៉ែត ដែលខ្ញុំជាមេធាវីរបស់ ឌុដម៉ាន ដែលជាមេធាវីរបស់ *អ៊ីដធីបូឌី ប៊ែងហ្គាឡូមេ*។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសូមជម្រាបភាគីនិងសាធារណជនថា នៅថ្ងៃនេះ នៅជិតលោកសាក្សី ឌុដម៉ាន គឺមានមេធាវីចំនួនពីររូប គឺលោក ថូដ ឡូវែល ហើយនិងលោក ចេសិន បារ៉ែត ដែលជាមេធាវី

ផ្ទាល់របស់សាក្សី។ ហើយគាត់ចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ក្នុងន័យពិនិត្យមើលលទ្ធភាពផ្នែកខាងសុខភាពរបស់លោកមេធាវី ឌុដម៉ាន នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

បាទ អរគុណលោក ថូដ ឡូវែល ហើយនិងលោក ចូសាន់ បារ៉ែត។

[០៨:១២:០៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ តទៅនេះ អង្គជំនុំជម្រះសូមជម្រាបសួរទៅសាក្សី។ តើលោកអាចប្រាប់អំពីនាមត្រកូល និងនាមខ្លួនរបស់លោក ជូនដល់អង្គជំនុំជម្រះបានដែរឬទេ លោកសាក្សី?

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំឈ្មោះ រីឆាដ ឌុដម៉ាន។

**ស៖** អរគុណ លោក រីឆាដ ឌុដម៉ាន ។ ហើយតើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំអត់យល់សំណួរលោកប្រធាន។

**ស៖** ថ្ងៃខែឆ្នាំកំណើតរបស់លោក តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ អំពីថ្ងៃខែឆ្នាំកំណើតរបស់លោក?

**ឆ៖** ខ្ញុំកើតនៅក្នុងខែឧសភា ឆ្នាំទី -- ថ្ងៃទី០៣ ឧសភា ឆ្នាំ១៩១៨។ បានន័យថា ខ្ញុំកើតកាលពី៩៦ឆ្នាំមុន។

**ស៖** បាទ អរគុណលោក ឌុដម៉ាន។ តើទីកន្លែងរស់នៅសព្វថ្ងៃរបស់លោកនៅទីកន្លែងណា? អាសយដ្ឋាន?

**ឆ៖** អាសយដ្ឋានរបស់ខ្ញុំ នៅក្នុងអេីលស្វែរមេដ ផ្លូវ១០ -- ៧០ លេខ -- ផ្លូវលេខ៧០ -- ៧០ -- ផ្លូវ *អេសរូត*--

**អ្នកបកប្រែ៖**

លោកប្រធាន អាចសុំឲ្យសាក្សី បញ្ជាក់អាសយដ្ឋានម្តងទៀត។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក រីឆាដ ឌុដម៉ាន អ្នកបកប្រែស្តាប់អត់ៗបានទេ សូមលោកបញ្ជាក់នូវអាសយដ្ឋាន

របស់លោកសាជាថ្មីម្តងទៀត។

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** បាទខ្ញុំទទួលអត់បានលោកប្រធាន។ អាសយដ្ឋានបច្ចុប្បន្នរបស់ខ្ញុំ គឺៗខ្ញុំជម្រាបអម្បាញ់មិញនេះឯង។ ខ្ញុំជម្រាបម្តងទៀត លេខចិត -- លេខ៧០ ផ្លូវស្វូរី – អេស-យូ-អ័រ-វ៉ាយ–រ៉ូដ – ផ្លូវនៅក្នុងទីក្រុងអេលស្វឹថ (អ៊ី-អិល-អិល-អេស-ដាប៊ែលយូ-អ័រ-ធី-អេច), *ម៉ែន* ០៤៦៥ -- *ម៉ែន* ០៤៦០៥។

**ស៖** តើលោកធ្វើអ្វីដែរសព្វថ្ងៃនេះ?

[០៨:១៥:០៦]

**ឆ៖** ខ្ញុំជាអ្នកនិពន្ធអាជីព បានន័យថា ខ្ញុំជាអ្នកនិពន្ធឯករាជ្យដែលសរសេរនិពន្ធដោយសម្រាប់ខ្លួនខ្ញុំ អាជីពខ្លួនខ្ញុំផ្ទាល់។

**ស៖** អរគុណលោករីឆាដ។ តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** សញ្ជាតិរបស់ខ្ញុំបាទ ខ្ញុំជាជនជាតិ ពលរដ្ឋអាមេរិក។

**ស៖** បាទ អរគុណលោក ឌុដម៉ាន។ តើលោក ឌុដម៉ាន ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថតាមជំនឿសាសនារបស់លោកជាមុនសិន តើលោកយល់ព្រមដែរឬទេ?

**ឆ៖** ខ្ញុំអាចធ្វើសម្បថបានលោកប្រធាន។ តើខ្ញុំគួរតែធ្វើឥឡូវនេះតែម្តង ឬយ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ចាំស្តាប់ការណែនាំរបស់ក្រឡាបញ្ជីសវនាការលោក រីឆាដ ឌុដម៉ាន។ លោក រ៉ូជឺ ហ្វីលីព សូមលោកណែនាំលោក ឌុដម៉ាន ឲ្យធ្វើសម្បថតាមជំនឿសាសនារបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។

**លោក រ៉ូជឺ ហ្វីលីព៖**

លោក ឌុដម៉ាន សូមធ្វើការអានសម្បថតាមខ្ញុំ ខ្ញុំសូមប្រកាសជាឱឡារិកថា "ខ្ញុំនិយាយតែការពិត ការពិតទាំងស្រុងគ្មានអ្វីក្រៅតែពីការពិត"។

**លោក រីឆាដ ឌុដម៉ាន៖**

ខ្ញុំសូមប្រកាសជាឱឡារិកថាខ្ញុំនឹងនិយាយតែការពិត ការពិតទាំងស្រុង គ្មានអ្វីក្រៅតែពីការពិត។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោក វីឆាដ ឌុដម៉ាន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺនួន ជា និង ខៀវ សំផន ទេ ហើយក៏មិនជាប់ញាតិ -- ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២នេះដែរ។ តើពិតមែនដែរឬទេ?

[០៩:១៧:៥៧]

**លោក វីឆាដ ឌុដម៉ាន៖**

**ឆ៖** ពិតជាត្រឹមត្រូវ លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនអំពីសិទ្ធិ និងករណីយកិច្ចរបស់លោក ឌុដម៉ាន ក្នុងនាមលោកជាសាក្សីក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធនៅក្នុងការឆ្លើយតបទៅនឹងសំណួរ ឬសុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយឬច្រើន ដែលដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ហើយករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកត្រូវឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានធ្វើ ឬបានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមសួរលោក។ លោក ឌុដម៉ាន តើលោកធ្លាប់ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ រយៈពេលកន្លងមក?

[០៩:១៩:១៧]

**ឆ៖** បាទ ខ្ញុំទទួលសំណួរអត់បានលោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយខ្ញុំបញ្ជាក់ម្ដងទៀត។ តើលោកធ្លាប់បានផ្ដល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារយៈពេលកន្លងមក?

**ឆ៖** អត់ដែរទេ លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបលោក វីឆាដ ឌុងម៉ាន ថាក្នុងអំឡុងពេលដែលលោកផ្តល់សក្ខីកម្ម ប្រសិនបើលោកត្រូវការឈប់សម្រាកនាពេលណាមួយ នោះសូមលោកជម្រាបមកអង្គជំនុំជម្រះបានដឹងជាមុន ដើម្បីអង្គជំនុំជម្រះលៃពេលវេលាសម្រាប់ឈប់សម្រាកនៅពាក់កណ្តាលទី ដែលលោកត្រូវការឈប់សម្រាក។ លោកយល់ទេ?

**ឆ៖** បាទ គឺ៤៥នាទី ក្រោយពីផ្តល់ការសក្ខីកម្មនេះ គឺអាចឈប់សម្រាកម្តង គឺអត់អីទេសម្រាប់ខ្ញុំ អាចធ្វើអ៊ីចឹងបាន ត្រឹម៤៥នាទី សម្រាកម្តង លោកប្រធាន។

[០៨:២០:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហមេធាវីការពារក្តីជនជាប់ចោទ នួន ជា ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី វីឆាត ឌុងម៉ាន មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយក្រុមមេធាវីការពារក្តី នួន ជា មានពេលវេលា១ម៉ោង ២០នាទី ក្នុងការសួរដេញដោលសាក្សី វីឆាត ឌុងម៉ាន។ សូមអញ្ជើញលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកស្រីចៅក្រម លោក លោកស្រីចៅក្រម។ សូមគោរពភាគីទាំងអស់។ លោកប្រធាន មុនពេលដែលខ្ញុំចាប់ផ្តើម ខ្ញុំសូមបញ្ជាក់ថា គឺខ្ញុំសង្ឃឹមថាខ្ញុំនឹងសួរសំណួរទៅកាន់សាក្សីនេះ ប្រហែលជា២ម៉ោង បាទចំពោះខាងខ្ញុំ។ ដោយសារខាង ខៀវ សំផន គាត់មិនមានសំណួរសួរច្រើន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមសួស្តី លោក វីឆាត ឌុងម៉ាន។

**លោក វីឆាត ឌុងម៉ាន៖**

**ឆ៖** បាទ សួស្តី។

[០៨:២២:០៥]

**ស៖** ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាសហមេធាវីអន្តរជាតិសម្រាប់ជនជាប់ចោទ នួន ជា។ ខ្ញុំមាន

សំណួរមួយចំនួនចង់សួរទៅកាន់លោក។ លោក ឌុដម៉ាន ខ្ញុំសួរសំណួរ -- ខ្ញុំមានសំណួរមួយចំនួនចង់សួរទៅកាន់លោក។ តើលោកឮស្ដាប់ខ្ញុំ -- ស្ដាប់ខ្ញុំឮដែរឬទេ?

**ឆ៖** បាទ ខ្ញុំអាចស្ដាប់បាន ក៏ប៉ុន្តែសូមឲ្យមេធាវីនិយាយឲ្យបានយឺតៗ ដើម្បីឲ្យខ្ញុំអាចទទួលសំឡេងបាន។

**ស៖** បាទ ជាការពិត ខ្ញុំអាចធ្វើទៅបាន។ លោក ឌុដម៉ាន ខ្ញុំសូមសួរលោក ដោយសារពេលវេលាយើងខ្លី ហើយខ្ញុំសួរលោកដោយសង្ខេប សូមឲ្យលោកធ្វើការរៀបរាប់នូវប្រវត្តិរូបរបស់លោក ហើយប្រសិនបើខ្ញុំលើកឡើងចំណុចណាមួយខុសនោះ គឺថាសូមឲ្យលោកកែតម្រូវរបស់ខ្ញុំ -- កែតម្រូវកំហុសដែលខ្ញុំលើកឡើង។ ដូចដែលលោកបានលើកឡើងរួចមកហើយ លោកបានកើតនៅក្នុងឆ្នាំ ១៩១៨ បានន័យថា នៅក្នុងខែដែលសង្គ្រាមលោកលើកទី១កំពុងតែលុកលុយនាពេលនោះ។ លោកបញ្ចប់ការសិក្សានៅស្ពេនហ្វីត ឆ្នាំ១៩៥៤ ផ្នែកកាសែត។ ខ្ញុំក៏ដឹងថាលោកក៏ជាទ័ពជើងទឹកនៅក្នុងសង្គ្រាមលោកលើកទី២ផងដែរ។ ខ្ញុំជឿថាលោកធ្វើការងារចាប់ផ្ដើមធ្វើការងាជាអ្នកកាសែតនៅក្នុងឆ្នាំ ១៩៤៩ ហើយលោកធ្វើការងារនេះ រយៈពេល៣១ឆ្នាំជាប់គ្នា។ លោក ឌុដម៉ាន ខ្ញុំជឿថា លោកបានធ្វើដំណើរទៅកាន់បដិវត្តន៍គុយបាដែលវាពាក់ព័ន្ធទៅនឹងការធ្វើឃាតលោក កេណ្ណឌី ហើយលោកក៏បានធ្វើដំណើរដឹងអំពីសង្គ្រាមវៀតណាម និងជម្លោះដទៃទៀតនៅក្នុងពិភពលោកផងដែរ។

នៅក្នុងឆ្នាំ១៩៧០ លោកបានចំណាយពេល៤០ថ្ងៃ ពាក់ព័ន្ធទៅនឹងបញ្ហាវៀតកុង នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ១៩៩៣ លោកបានទទួលស្នាដៃ ដែលជាពានរង្វាន់សម្រាប់អ្នកកាសែតដែលមានកេរ្តិ៍ឈ្មោះល្បីនិងស្វះស្វែងការងារ។ លោក ឌុដម៉ាន ខ្ញុំពិតជាចាប់អារម្មណ៍ទៅលើគុណវុឌ្ឍិគុណសម្បត្តិការងាររបស់លោក។ ហើយខ្ញុំក៏សូមកោតសរសើរចំពោះលោកដែលមកដល់ពេលនេះ ៩៧ឆ្នាំហើយ លោកនៅតែអាចមានលទ្ធភាពផ្ដល់សក្ខីកម្ម និងស្ម័គ្រចិត្តផ្ដល់សក្ខីកម្មជូនតុលាការ។ នេះជាការសង្ខេបទៅលើប្រវត្តិរូបរបស់លោក ដើម្បីឲ្យយើងសាកសួរ ផ្ដល់សក្ខី -- សាកសួរលោកនៅពេលដែលលោកផ្ដល់សក្ខីកម្ម។ តើលោកមានអ្វីចង់បន្ថែមដែរឬទេ?

[០៩:២៥:៤៨]

**ឆ៖** ពិតជាត្រឹមត្រូវ ខ្ញុំចាប់ផ្ដើមជាអ្នករាយការណ៍ មុនឆ្នាំ១៩៤៩ទៅទៀត។ ហើយលោកបានលើកឡើងយ៉ាងត្រឹមត្រូវពាក់ព័ន្ធនឹងអាជីពការងាររបស់ខ្ញុំ។ ពិតជាត្រឹមត្រូវហើយលោកមេធាវី។

**ស៖** សូមអរគុណលោក ឌុដម៉ាន ខ្ញុំមានសំណួរចង់សួរបន្តមួយចំនួនបន្ថែមទៀត ទៀតពាក់ព័ន្ធ

នឹងប្រវត្តិរូបរបស់លោក។ តើលោកអាចជម្រាបអង្គជំនុំជម្រះសាលាដំបូងបានដែរឬទេ ហេតុអ្វីបានជាលោកបានទទួលនូវពានរង្វាន់អ្នកកាសែត ដូចដែលខ្ញុំបានលើកឡើងពីខាងដើម?

**ឆ៖** ខ្ញុំអត់ដឹងទេ គឺជាការវិនិច្ឆ័យរបស់អ្នកដែលផ្ដល់ពានរង្វាន់ផ្ទាល់របស់គេ។

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែនៅពេលដែលលោកបានទទួលពានរង្វាន់មួយនេះ ដែលលោកបានទទួលនៅពេលនោះ ប្រាកដជាគេប្រាប់ហេតុផលហើយ ថាហេតុអ្វីបានជាគេផ្ដល់ជូនលោក?

**ឆ៖** គេលើកឡើងថា ខ្ញុំជាអ្នករាយការណ៍មួយដ៏ល្អ។

**ស៖** សូមអរគុណលោក ឌុដម៉ាន។ សំណួរបន្ទាប់របស់ខ្ញុំ ខ្ញុំចង់សួរលោកថា តើលោកអាចរៀបរាប់លម្អិតអំពីការងាររបស់លោកក្នុងនាមជាអ្នកកាសែតដែរឬទេ ជាពិសេសពាក់ព័ន្ធទៅនឹងការចុះផ្សាយ ការពាក់ព័ន្ធរបស់អាមេរិកនៅក្នុងសង្គ្រាមវៀតណាម និងកម្ពុជា ជាពិសេសនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០?

[០៨:២៧:៣២]

**ឆ៖** អ្នកនិពន្ធនាយករបស់ខ្ញុំបានបញ្ជូនខ្ញុំម្ដងហើយម្ដងទៀតមកប្រទេសវៀតណាម និងប្រទេសកម្ពុជាជាច្រើនដង។ ហើយខ្ញុំបានស្នាក់នៅក្នុងតំបន់ទាំងពីរនេះ ប្រទេសទាំងពីរនេះ រយៈពេលពីរបីសប្ដាហ៍។ ហើយខ្ញុំបានសរសេរអត្ថបទជាច្រើនពាក់ព័ន្ធទៅនឹងជម្លោះដែលបានកើតឡើងនៅក្នុងប្រទេសទាំងពីរនេះ។

**ស៖** តើលោកអាចដឹងចាំទេ ថាតើលោកមកឥណ្ឌូចិនណានៅក្នុងឆ្នាំទសវត្សរ៍៧០នេះ ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ប្រហែលជាប្អូនដប់ដង។

**ស៖** លោក ឌុដម៉ាន តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ អំពីរយៈពេល៤០ថ្ងៃដែលលោកមក ចុះផ្សាយអំពីវៀតកុងនៅក្នុងប្រទេសកម្ពុជា? ខ្ញុំបានអានអត្ថបទរបស់លោក។ ថាតើវាប៉ះពាល់យ៉ាងម៉េចពាក់ព័ន្ធនឹងបញ្ហាវៀតកុងនេះ នៅក្នុងសង្គ្រាមស៊ីវិលប្រទេសកម្ពុជា ចន្លោះឆ្នាំ៧០ ទៅដល់ ៧៥នោះ?

**ឆ៖** ខ្ញុំអត់យល់សំណួរលោកទេ លោកមេធាវី។

**ស៖** លោកត្រូវបានគេចាប់ឃុំនៅក្នុងប្រទេសកម្ពុជារយៈពេល៤០ថ្ងៃ ដោយអ្នកវៀតកុង មកពីខាងវៀតណាមខាងត្បូង គឺចាប់ឃុំលោក៤០ថ្ងៃ។ លោកសរសេរសៀវភៅមួយពាក់ព័ន្ធទៅនឹងបញ្ហា

ហ្នឹង។ តើលោកអាចជម្រាបលម្អិតបន្ថែម ក្នុងរយៈពេលដែលគេឃុំខ្លួនលោកនោះ ថាតើការឃុំខ្លួននោះវាប៉ះពាល់ និងមានឥទ្ធិពលយ៉ាងម៉េចចំពោះការយល់ឃើញរបស់លោកទៅលើសង្គ្រាមដែលលុកលុយនៅក្នុងប្រទេសកម្ពុជានេះ?

[០៨:២៩:២៩]

**ឆ៖** ខ្ញុំសូមសង្ខេបថា ខ្ញុំបានដឹងនូវព័ត៌មានថាវៀតកុងជាអ្នកឃុំខ្លួនខ្ញុំ។ បាទ គឺគេជួយខ្ញុំឲ្យមានភាពរាក់ទាក់រួសរាយណាស់។ ខ្ញុំគិតថាពួកវៀតកុង គឺជាអ្នកបុគ្គល ជាមនុស្សដែលមានចិត្តដែរ មិនមែនជាខ្មាំងសត្រូវចំពោះយើងនោះឡើយ។

**ស៖** តើវាមានធ្វើឲ្យលោកយល់ផ្សេងពីហ្នឹងដែរឬទេ ពាក់ព័ន្ធនឹងសង្គ្រាមដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ឬក៏វាពិបាកសម្រាប់លោកក្នុងការលើកឡើងចំណុចនេះ?

**ឆ៖** ខ្ញុំដូចជាមិនចាំនោះទេ ការចងចាំរបស់ខ្ញុំវាបានផ្លាស់ប្តូរ។ ដូច្នេះ ខ្ញុំអត់ចាំទេ។

**ស៖** សូមអរគុណលោក ឌុដម៉ាន។ សួរបន្តទៀត ក្រោយ -- បានន័យថា ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងឆ្នាំក្រោយៗមកទៀត តើលោកចាត់ទុកខ្លួនលោកថាអ្នកជំនាញទៅលើគោលការណ៍ៗនយោបាយរបស់បរទេស របស់វៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលចាត់ទុកថា ខ្ញុំជាអ្នកជំនាញទេ ខ្ញុំតែងតែសិក្សាបន្តរហូតពាក់ព័ន្ធនឹងនយោបាយបរទេសរបស់វៀតណាម។

**ស៖** ពិតជាត្រឹមត្រូវ។ តើលោកមានជំនាញផ្សេងទៀតដែរឬទេ? ដែលវាពាក់ -- ជាពិសេសពាក់ព័ន្ធទៅនឹងនយោបាយបរទេស នយោបាយ គោលនយោបាយបរទេសរបស់វៀតណាមនោះ។ តើលោកមានជំនាញអ្វីផ្សេងដែលទៀតដែរឬទេ?

[០៨:៣១:៣៦]

**ឆ៖** ខ្ញុំផ្សព្វផ្សាយក្រសួងការបរទេស ហើយនិងសុន្ទរកថាគោលនយោបាយ និងសកម្មភាពផ្សេងៗ គឺខ្ញុំមិនអាច -- ខ្ញុំមិនដឹងថាខ្ញុំត្រូវឆ្លើយអ្វីលើសពីហ្នឹងទេ។

**ស៖** ខ្ញុំយល់ថាសំណួររបស់ខ្ញុំពិបាក ក៏ប៉ុន្តែខ្ញុំសូមសួរបន្តទៅមុខទៀត។ ខ្ញុំសូមសួរនៅក្នុងឆ្នាំ ១៩៩០ ទសវត្សរ៍ឆ្នាំ១៩៩០ បានន័យថាកាលពី២៥ឆ្នាំមុន។ ខ្ញុំសូមសួរទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារតែថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩០ លោកបានសរសេរអត្ថបទមួយនៅក្នុងកាសែតញូវយ៉ក។ តើលោកចាំទេថាលោកធ្លាប់បានសរសេរអត្ថបទមួយនៅក្នុងកាសែតញូវយ៉កថាមស៍?

**ឆ៖** ខ្ញុំមិនចាំទេ ក៏ប៉ុន្តែអត្ថបទនេះបានផលិតបោះពុម្ពផ្សាយ -- បានន័យថាព្រឹនឲ្យខ្ញុំមើលកាលពីយប់មិញ។ ដូច្នេះ ខ្ញុំមិនទាន់បានមើលនៅឡើយទេ។

**ស៖** តើជាការល្អទេ ប្រសិនបើលោកចំណាយពេលពីរបីនាទីទៅ មើលអត្ថបទដែលបានគេបានបោះពុម្ព ព្រឹនឲ្យលោកហ្នឹង កាលពីយប់មិញនោះ ឬក៏លោកចង់ឲ្យខ្ញុំសួរសំណួរតែម្តង?

**ឆ៖** ប្រសិនបើលោកមេធាវីទុកពេលឲ្យខ្ញុំពីរបីនាទី ខ្ញុំមើលឥឡូវនេះតែម្តង។ ខ្ញុំអានតែម្តង។

**ស៖** បាទ សូមអញ្ជើញលោក ឌុដម៉ាន សូមអញ្ជើញចំណាយពេលអានទៅ។

*(សាក្សីអានឯកសារ)*

**លោក វ៉ិចទ័រ កូប៉េ៖**

ក្នុងខណៈពេលមេធាវីកំពុង -- ក្នុងខណៈពេលៗដែលសាក្សីកំពុងតែអាន ខ្ញុំលើកឡើងឯកសារ E307/5.2.16, អង់គ្លេស ERN គឺ01002091, បារាំងលេខ ERNគឺមានលេខ 0107246, ខ្មែរលេខ ERN គឺ0107091 ទៅដល់ 94។

[០៨:៣៦:៤៤]

**លោក រីឆាត ឌុដម៉ាន៖**

**ឆ៖** ខ្ញុំចប់ហើយ អានចប់ហើយលោកមេធាវី។

**សួរដោយ លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោក ឌុដម៉ាន។ ខ្ញុំដឹងថាខ្ញុំបានសួរលោកអំពីហេតុការណ៍កើតឡើងប្រហែលជាជិត២៥ឆ្នាំមុន។ តើលោកនៅចាំទេ តើលោកបានសរសេរអ្វីនៅក្នុងកាសែតញូវយ៉កថាមស៍?

**ឆ៖** តើលោក -- ខ្ញុំ -- សួរខ្ញុំថា តើខ្ញុំចាំការសេរសេរអត្ថបទនេះយ៉ាងម៉េច?

**ស៖** តើលោកអាចចាំទេ ហេតុអ្វីបានជាលោកសរសេរអត្ថបទនេះ?

**ឆ៖** ខ្ញុំស្តាប់សំណួរអត់បានទេ លោកមេធាវី។

**ស៖** តើលោកនៅចាំ ហេតុផលអ្វីដែលនាំឲ្យលោកសរសេរអត្ថបទនេះ? តើមានអ្វីដែលជំរុញឲ្យលោកសរសេរអត្ថបទមួយនេះ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** តើលោកអាចជម្រាបបានទេថា លោក ឌុដម៉ាន?

**ឆ៖** ខ្ញុំបានមកទស្សនកិច្ចកម្ពុជា មនុស្សជាច្រើនបានប្រាប់ខ្ញុំនូវប្រទេសរបស់ខ្ញុំ និងនៅទីកន្លែង

ផ្សេងទៀត។ តើខ្ញុំត្រូវគិតអំពីអ្វី ក្នុងនាមជាអ្នករាយការណ៍។ ខ្ញុំចង់ឃើញផ្ទាល់ភ្នែក ហើយសម្រេចចិត្តដោយខ្លួនឯង មិនមែនសរសេរអ្វីដែលខ្ញុំត្រូវតែសរសេរនោះទេ។ ខ្ញុំបានមកពិនិត្យមើលអំពីសញ្ញាណាមួយដែលនិយាយអំពីការបោះបង់ចោល និងភាពឃោរឃៅ និងខ្ញុំចង់ឃើញអំពីការសម្លាប់រង្គាលក្នុងទ្រង់ទ្រាយធំ ទៅលើប្រជាជន។ ខ្ញុំបានស្តាប់ឮ គេបានប្រាប់ខ្ញុំថាហេតុការណ៍មួយចំនួនបានកើតឡើង ក៏ប៉ុន្តែការប្រាប់របស់អ្នកទាំងអស់នោះ គឺថាមិនអាចដែលខ្ញុំមកធ្វើការវិនិច្ឆ័យទៅលើការកើតឡើងទាំងស្រុងនៃការសម្លាប់រង្គាលនោះទេ។ ហើយខ្ញុំមិនដឹងថាតើគេយល់យ៉ាងម៉េចនោះទេ ក៏ប៉ុន្តែអ្នកសរសេរកាសែត យើងត្រូវតែចោទជាសំណួរ និងនៅតែសង្ស័យនូវអ្វីដែលគេប្រាប់យើង ហើយអ្វីដែលយើងបានដឹង។ ខ្ញុំមកធ្វើការងារហ្នឹងដោយហ្មត់ចត់ និងយកចិត្តទុកដាក់បំផុត។ ហើយចំណុចហ្នឹងហើយ ដែលវាជាការជំរុញទឹកចិត្តដល់ខ្ញុំ ហើយខ្ញុំបានអានហ្នឹង ហើយខ្ញុំបានសរសេរនូវអ្វីដែលលោកបានយល់និងបានឃើញនេះ។

[០៨:៣៩:៣៥]

**ស៖** ជារួមមក តើលោកអាចជម្រាបបានដែរឬទេថា នៅថ្ងៃនេះលោកនៅតែរក្សាថា ខ្លឹមសារដែលនៅក្នុងអត្ថបទនេះ វានៅតែត្រឹមត្រូវ ហើយលោកនៅតែយល់ដូច្នេះ?

**ឆ៖** ចាប់តាំងពីពេលនោះមក ខ្ញុំបានអានអត្ថបទជាច្រើននូវអ្វីដែលបានកើតឡើងក្នុងរបប ប៉ុល ពត ។ ហើយខ្ញុំបានមើលប្រភពផ្សេងទៀត ខ្ញុំបានក៏និយាយជាមួយប្រភពផ្សេងទៀតផងដែរ ដែលគេសរសេរអំពីបញ្ហាហ្នឹង។ ហើយខ្ញុំនៅតែមានការសង្ស័យអំពីអ្នកដែលសរសេររឿងរ៉ាវដែលបានសរសេរនោះ ដោយ -- ហើយខ្ញុំសូមបញ្ជាក់ថា ចំពោះចំណងជើងនេះ វាហាក់ដូចជាចម្លែកបន្តិច ខ្ញុំមិនបានសរសេរចំណងជើងហ្នឹងខ្លួនឯងនោះទេ។ នេះជាអ្វីដែលខ្ញុំបានឃើញនៅពេលនោះ បានន័យខ្ញុំដាក់ចំណងជើងនេះតែម្តង។

**ស៖** ខ្ញុំសូមអាននូវចំណុចដកស្រង់មួយ ឬក៏ពីរចេញពីអត្ថបទរបស់លោក។ ហើយខ្ញុំសូមសួរសំណួរបន្ត។ តើមានន័យយ៉ាងម៉េចនៅពេលដែលលោកសរសេរអត្ថបទមួយពីរ -- ចំណុចមួយពីរដែលខ្ញុំដកស្រង់នេះ។

**ឆ៖** បាទ សូមអញ្ជើញលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអំមិញលើកឡើងអំពីលេខ ERN ហើយ ដូច្នេះហើយខ្ញុំដឹងថា លោក លោកស្រី

ទាំងអស់ ភាគីទាំងអស់មានឯកសារនៅចំពោះមុខហើយ ERN នៅចំពោះមុខរួចមកហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្វីដែលខ្ញុំចង់អាននោះគឺថានៅក្នុងជួរទី២ លោក ឌុដម៉ាន។ មុនពេលដែលលោកបោះបង់ចោលសម្ព័ន្ធប្រឆាំងនេះ យើងគួរតែក្រឡេកមើលម្ដងទៀត ទៅលើបុរសដែលយើងចូលចិត្តស្អប់ ដោយក្រឡេកមើលតាមការយល់ដឹងជាធម្មតា។ តើលោកមានទេអត្ថបទហ្នឹង? ដែលថា "ប៉ុល ពត និងខ្មែរក្រហមគឺជាមនុស្សជ្រុលនិយម គ្មានហេតុផល ដែលបានអនុវត្តអំពើប្រល័យពូជសាសន៍ដោយចេតនាសម្លាប់ប្រជាពលរដ្ឋ ប្រជាជនកម្ពុជាចំនួនជាង១លាននាក់ ហើយបានបំផ្លាញសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា។ ភស្តុតាងសម្រាប់ជំនឿមិនប្រែប្រួលទាំងនេះ ភាគច្រើនគឺជារឿងរ៉ាវនៃការសន្និដ្ឋានចេញពីការ -- រឿងរៀបរាប់អំពីការសម្លាប់រង្គាលនៅភូមិមួយចំនួនដែលរឿងរ៉ាវ និងការសន្និដ្ឋានទាំងនោះពោរពេញដោយខ្លោចផ្សា ទោះបីគ្មានស្ថិតិបញ្ជាក់ក៏ដោយ។ ភស្តុតាងទាំងនោះ ភាគច្រើនចេញមកពីអ្នកដែលមានចំណាប់អារម្មណ៍ធ្វើឲ្យខូចឈ្មោះខ្មែរក្រហម គឺចេញពីជនភៀសខ្លួនកម្ពុជា ភាគច្រើនជាជនរងគ្រោះថ្នាក់កណ្ដាល ឬថ្នាក់ខ្ពស់នៅក្នុងបដិវត្តន៍របស់ប៉ុល ពត និងជនជាតិវៀតណាមដែលបានចូលយកទឹកដីកម្ពុជាអស់ជាច្រើន តាំងពីយូរមកហើយ។ សាយហ្គុនធ្លាប់ជាទីក្រុងមួយរបស់កម្ពុជា ហើយឥឡូវនេះវៀតណាមល្មោភចង់បានទាំងអស់។ ហាណូយដឹងពីល្បែងទំនាក់ទំនងសាធារណៈនេះ ម្យ៉ាងទៀតប៉ុល ពត និងរបបដូចឥសីរបស់គាត់ស្ទើរតែមិនបាច់ប្រឹងនិយាយរឿងរបស់ខ្លួនឡើយ"។

ខ្ញុំទទួលសញ្ញាមកថា ឲ្យខ្ញុំអានបន្តិច -- អានយឺតបន្តិចដើម្បីឲ្យអ្នកបកប្រែបកតាមទាន់។ សំណួរដំបូងដែលខ្ញុំចង់សួរលោក លោក ឌុដម៉ាន គឺតើលោកចាំ តើហេតុអ្វីបានជានាំឲ្យលោកសរសេរនូវចំណុចសន្និដ្ឋានមួយដែលលោកបានលើកឡើងថា វាគឺដោយសារតែមានអ្នកចង់បង្ខូចឈ្មោះខ្មែរ-ក្រហមទាំងអស់នោះដែលជាអ្នករៀបរាប់រឿងរ៉ាវទាំងអស់នេះ។ ហើយរឿងហ្នឹងគឺចេញមកពីជនភៀសខ្លួនកម្ពុជា?

[០៨:៤៣:៤៦]

**ឆ៖** ខ្ញុំមិនចាំការសន្ទនាដែលខ្ញុំជជែកជាមួយអ្នកទាំងអស់នោះ នាពេលនោះឡើយ។ ក៏ប៉ុន្តែគេប្រាប់ខ្ញុំអំពីទាំងអស់ហ្នឹង រឿងរ៉ាវទាំងអស់ហ្នឹងគឺជនភៀសខ្លួនកម្ពុជា ប្រាប់ខ្ញុំរឿងរ៉ាវទាំងអស់ហ្នឹង។ ខ្ញុំបានសរសេរដូចដែលលោកដកស្រង់អ៊ីចឹង។ ក៏ប៉ុន្តែយើងត្រូវក្រឡេកមើលមួយជ្រុងផ្សេងទៀត នៅពេលដែលយើងក្រឡេកមើលមួយជ្រុងផ្សេងទៀត ហើយយើងនឹងសញ្ជឹងគិតទៅ សញ្ជឹងគិតទៅលើ

ភស្តុតាងទៅ ភស្តុតាងនឹងបង្ហាញគាំទ្រការពិតថា មានការកាប់សម្លាប់រង្គាលកើតឡើងមែន។ នៅពេលនោះ ខ្ញុំបានសរសេរអត្ថបទមួយជាមួយអ្នករាយការណ៍មានចំណុចសង្ស័យទៅលើចំណុចហ្នឹង ហើយនិងអ្វីដែលយើងបានដឹង។ ហើយនៅពេលនេះ ខ្ញុំបានដឹងច្រើនរឿងរ៉ាវហ្នឹងជាងពេលនោះទៀត។

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀតពាក់ព័ន្ធទៅនឹងកថាខណ្ឌដែលខ្ញុំបានអានអម្បាញ់មិញលោកឌុដម៉ាន។ តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកសរសេរថា "ហាណូយដឹងល្បែងទំនាក់ទំនងសាធារណៈនេះ។ ម៉្យាងទៀតប៉ុល ពត និងរបបឥសីរបស់គាត់ស្ទើរតែមិនបាច់ប្រឹងនិយាយរឿងរ៉ាវរបស់ខ្លួនឡើយ"។ តើលោកមានន័យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំអត់ចាំទេ តើខ្ញុំបានទទួលព័ត៌មានចំណុចនេះមកពីណា។ បាទ ខ្ញុំពិតជាមិនចាំទេត្រង់ចំណុចហ្នឹង។ ខ្ញុំមិនបដិសេធថា ខ្ញុំជាអ្នកសរសេរទេ មិនមែនខ្ញុំបដិសេធថាខ្ញុំសរសេរទេ ក៏ប៉ុន្តែខ្ញុំអត់ចាំថា តើខ្ញុំបានទទួលព័ត៌មានហ្នឹងមកពីណា?

[០៨:៤៥:៣៧]

**ស៖** គឺមានចំណុចមួយទៀត ចំណុចទី២ដែលខ្ញុំសូមចង់អាន សួរលោកសំណួរមួយចំនួនផងដែរ គឺកថាខណ្ឌដែលឆ្លុះបញ្ចាំងអំពីទស្សនកិច្ចរបស់លោកនៅក្នុងឆ្នាំ១៩៧៨ នៅកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកូឡោនទី៤ នៃអត្ថបទរបស់លោកដែលចាប់ផ្ដើមដោយពាក្យថា "ទោះបីយ៉ាងណាក៏ដោយ..." តើលោករកឃើញទេ ចំណុចដែលខ្ញុំគ្រោងនឹងអានឲ្យលោកស្ដាប់នោះ។ "ទោះយ៉ាងណាក៏ដោយ ព័ត៌មានដែលខ្ញុំបានទទួលពីមុននោះ គឺភាគច្រើននាំឲ្យមានការយល់ខុស។ ខ្ញុំបានអង្កេតមើលប្រជាជនកម្ពុជាជាច្រើនរយនាក់ ច្រើនមែនទេ ដែលខ្ញុំគិតថាត្រូវបានរៀបចំដើម្បីជួយជាប្រយោជន៍ខ្ញុំ។ ខ្ញុំបានឃើញប្រជាជនដែលជាទូទៅមានសុខភាពល្អ មានមនុស្សចម្រុះគ្នា ជាធម្មតាគឺមានមនុស្សប្រុស មនុស្សស្រី និងកុមារ រួមទាំងកូនង៉ែតគេបីក្នុងដៃផងដែរ ព្រមទាំងបានឃើញម្ដាយមើលថែទាំជាច្រើននាក់។ ខ្ញុំរកមិនឃើញមានមនុស្សពោះហើម និងសក់ស្រអាប់គ្រើមពណ៌ត្នោតទេ។ ម៉ោងធ្វើការគឺចាប់ពីម៉ោងប្រាំពីរព្រឹក ដល់ម៉ោងប្រាំពីរល្ងាច មិនមែនថាមិនសមហេតុផលទេ ក្នុងរដូវប្រមូលផល។ រោងចក្រកៅស៊ូធម្មជាតិមួយកន្លែង រោងចក្រផលិតឱសថមួយកន្លែង និងរោងចក្រតម្បាញមួយកន្លែងហាក់ដូចជាកំពុងដំណើរការប្រកបដោយប្រសិទ្ធផល។ ការនាំចេញអង្ករស្រូវបានចាប់ផ្ដើមឡើងវិញក្នុងកម្រិតមធ្យមដូចបានបញ្ជាក់ដោយក្រសួងកសិកម្មសហរដ្ឋអាមេរិកនាពេលក្រោយមកទៀត"។ លោក ឌុដម៉ាន តើលោកនៅចាំទេថា មុនពេលដែលលោកសរសេរចំណុចមួយនេះនៅក្នុងកាសែតញូវយ៉កថាមស៍ ក្នុង

ឆ្នាំ១៩៨០។ តើលោកបានអានមើលរបាយការណ៍របស់លោកដែលសរសេរឡើងនៅក្នុងឆ្នាំ១៩៧៥ដែរឬទេ? តើលោកពិតបានអានមើលរបាយការណ៍ ឆ្នាំ១៩៧៥ នុ៎ងដែរឬទេ?

**ឆ៖** ខ្ញុំទទួលសំណួរលោកអត់បានទេ សូមលោកសួរឡើងវិញ។

**ស៖** បាទ ខ្ញុំអាចសួរឡើងវិញបាន។ ខ្ញុំបានដកស្រង់ចំណុចមួយចំនួននៅក្នុងអត្ថបទរបស់លោកដែលលោកពាក់ព័ន្ធនឹងការទស្សនកិច្ចរបស់លោកក្នុងឆ្នាំ១៩៧៨ នៅកម្ពុជាប្រជាធិបតេយ្យ។ មុនពេលដែលលោកសរសេរអត្ថបទនេះ តើលោកនៅចាំទេថា មុនពេលដែលលោកសរសេរអត្ថបទមួយនេះលោកបានអានរបាយការណ៍មួយនៅក្នុងឆ្នាំ១៩៧៥?

[០៨:៤៨:៤៧]

**ឆ៖** ខ្ញុំអត់ចាំ ថាចំណុចនេះវាពាក់ព័ន្ធនឹងអ្វីដែលខ្ញុំបានឃើញពីមុននោះទេ។ ចំណុចដែលលោកអានចាប់ផ្ដើមពី "ទោះបីយ៉ាងណាក៏ដោយនោះ..." ខ្ញុំចាំថា ខ្ញុំបានសរសេរចំណុចហ្នឹងមែន ហើយខ្ញុំបានពិនិត្យមើលរកសញ្ញាណាមួយដែលបង្ហាញអំពីការរំលោភបំពានទៅលើប្រជាជន។ ខ្ញុំបានសរសេរនូវអ្វីដែលខ្ញុំបានឃើញតែប៉ុណ្ណោះ។

**ស៖** ខ្ញុំសួរសំណួរបន្តមួយទៀត ផ្សេងពីហ្នឹងបន្តិច។ តើលោកយល់ថា នៅពេលដែលលោកសរសេរអត្ថបទមួយហ្នឹងនៅក្នុងកាសែតញូវយ៉កថាមស៍ ថារបាយការណ៍ឆ្នាំ១៩៧៥មួយរបស់លោក គឺផ្ទុះបញ្ចាំងនូវបទពិសោធន៍របស់លោកដែលមកទស្សនកិច្ចនៅក្នុងកម្ពុជាប្រជាធិបតេយ្យក្នុង ឆ្នាំ១៩៧៨ ដែរឬទេ?

**ឆ៖** ខ្ញុំពិតជាចាប់សំណួររបស់លោកអត់បានទេ លោកមេធាវី។

[០៨:៥០:១២]

**ស៖** សំណួររបស់ខ្ញុំគឺ ខ្ញុំចង់យល់ថាតើនៅក្នុងឆ្នាំ១៩៨០ នៅពេលដែលលោកសរសេរអត្ថបទហ្នឹង តើលោកបានដកស្រង់បទពិសោធន៍ពីទស្សនកិច្ចរបស់លោកនាឆ្នាំមុនៗនោះដែរឬទេ? ហើយវាផ្ទុះបញ្ចាំងអំពីបទពិសោធន៍នៃទស្សនកិច្ចរបស់លោកកាលពីឆ្នាំមុនៗដែរឬទេ? ឬក៏តើលោកពិតជាបានមើលនូវរបាយការណ៍ នៅក្នុងឆ្នាំ១៩៧០ជាងរបស់លោក ហើយយកមកសរសេរនៅក្នុងអត្ថបទរបស់លោកក្នុងឆ្នាំ១៩៨០នេះដែរឬទេ?

**ឆ៖** មានបទពិសោធន៍ពីរដោយឡែកពីគ្នា។ នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំខ្លួនឯងនេះគឺត្រូវបានគំរាមហើយទំនងជាអាចត្រូវបានគេសម្លាប់ផង។ នៅក្នុងឆ្នាំ១៩៨០ ខ្ញុំបានមករកភស្តុតាងដែលវាគាំទ្រអំពី

សំណួរអ្នកដែលអានបទអត្ថនោះ គេចោទសួរអំពីប្រទេសកម្ពុជា។ ខ្ញុំបានសរសេរនូវអ្វីដែលខ្ញុំបានឃើញ ហើយនៅក្នុងអត្ថបទនេះ ខ្ញុំបានសរសេរនូវអ្វីដែលបានកើតឡើង។ ខ្ញុំដូចជាមិនឆ្លើយតបទៅនឹងសំណួររបស់លោក ក៏ប៉ុន្តែនេះជាចម្លើយរបស់ខ្ញុំ។

[០៨:៥១:៤២]

**ស៖** ខ្ញុំចង់ស្វែងយល់ បានន័យថា ១១ឆ្នាំក្រោយពីលោកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនោះ គឺលោកបានឃើញហេតុការណ៍ហ្នឹង វាផ្សេងពីទស្សនកិច្ចរបស់លោកនាពេលមុន។ តើវាបានផ្លាស់ប្តូរការយល់ឃើញរបស់លោកទៅនឹងឆ្នាំ៧៨ដែរឬទេ? ឬក៏ឆ្នាំ១៩៩០នេះ គឺវានៅតែបង្ហាញនូវអ្វីដូចដែលលោកបានសរសេរនៅក្នុងអត្ថបទរបស់លោក?

**ឆ៖** ខ្ញុំអត់មានឃើញចំណុចខ្ទាស់គ្នារវាងចំណុចទាំងពីរដូចដែលលោកបានលើកឡើងនោះទេ។ ខ្ញុំបានសរសេរនូវអ្វីដែលខ្ញុំបានឆ្លងកាត់ និងអ្វីដែលខ្ញុំបានឃើញតែប៉ុណ្ណោះ។

**ស៖** សូមអរគុណលោក ឌុដម៉ាន។ ហេតុផលមួយទៀត ដែលខ្ញុំសួរសំណួរលោកហ្នឹង គឺដោយសារតែខ្ញុំបានសួរ អេលីហ្សាបេត បេកយ័រ ក៏បានសួរគាត់ ទៅនឹងលើសំណួរ ពាក់ព័ន្ធទៅនឹងអត្ថបទរបស់លោកមួយនេះផងដែរ។ លោកស្រី បេកយ័រ បានអានអត្ថបទរបស់លោកមួយច្បាប់ហ្នឹង ហើយគាត់បានផ្តល់សក្ខីកម្មផងដែរ។ ខ្ញុំសូមដកស្រង់សម្តីរបស់គាត់តែម្តង ហើយគាត់រិះគន់ទៅលើអត្ថបទដែលលោកបានសរសេរនេះ។ គាត់បានលើកឡើងថា គាត់មិនឯកភាពនូវអ្វីដែលលោកបានលើកឡើងសរសេរឡើងនៅក្នុងអត្ថបទនេះទេ។

[០៨:៥៣:២០]

ប្រសិនបើអនុញ្ញាត ខ្ញុំនឹងអានចម្លើយរបស់ បេកយ័រ ហើយខ្ញុំសូមឲ្យលោកធ្វើប្រតិកម្ម ផ្តល់ប្រតិកម្មទៅលើចម្លើយដែល បេកយ័រ បានឆ្លើយវិញម្តង។ ខ្ញុំបានសួរ អេលីហ្សាបេត បេកយ័រ ថាតើលោកស្រី អេលីហ្សាបេត បេកយ័រ -- ខ្ញុំអានយោងលើអត្ថបទ E1/260 ការផ្តល់សក្ខីកម្មនៅក្នុងថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥ គឺចន្លោះម៉ោងដប់បី ហាសិបមួយ ទៅដល់ម៉ោងពីររសៀល។ ខ្ញុំបានសួរសំណួរទៅកាន់ អេលីហ្សាបេត បេកយ័រ “តើលោកស្រីមានយោបល់យ៉ាងម៉េច ទៅលើអត្ថបទមួយ ដែលលោក ឌុដម៉ាន បានសរសេរ?” លោកស្រី បេកយ័រ ឆ្លើយថា៖ ខ្ញុំមិនឯកភាពទេ។ នៅត្រឹមឆ្នាំ១៩៩០ នៅពេលដែលបោះពុម្ពអត្ថបទនេះ កំណត់ហេតុរបាយការណ៍នៅទួលស្លែងបានបើកចំហឲ្យមើលជាច្រើនឆ្នាំរួចមកហើយ ហើយ ឌុដម៉ាន គាត់ចូលនិវត្តន៍ គាត់មិនដែលត្រឡប់មកចូលប្រទេសកម្ពុជា

ក្រោយឆ្នាំ១៩៧៨នោះទេ។ ហើយខ្ញុំមិនឯកភាពជាមួយនឹងគាត់ អ្វីដែលគាត់សរសេរនោះទេ ដោយសារមានភស្តុតាងផ្ទុយពីចំណុចហ្នឹង"។ នៅក្នុងសក្ខីកម្មរបស់ អេលីហ្សាបេត បេកយ័រ – អេលីហ្សាបេត បេកយ័រ បានឆ្លើយថា "គំនិតរបស់ ឌុង ហ្នឹង គឺថាវាហួសសម័យ។ គាត់មិនបានលើកអំពីឯកសារជាច្រើនទៀតក្រោយមកបានរកឃើញ ក្រោយវៀតណាមចូលលុកលុយ។ ហេតុផលដែលយើងបើកសវនាការជំនុំជម្រះនៅពេលនេះ ដោយសារតែភស្តុតាងមានច្រើនណាស់ ក៏ប៉ុន្តែដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង ខ្ញុំកោតសរសើរ និងសូមសរសើរចំពោះលោក ឌុង ក៏ប៉ុន្តែវាមានភស្តុតាងច្រើនទៀតដែលរកឃើញក្រោយរបបនេះ។ នេះជាផ្នែកមួយនៃសក្ខីកម្មរបស់ អេលីហ្សាបេត បេកយ័រ។

[០៨:៥៥:៣០]

ហើយពាក់ព័ន្ធនឹងទស្សនកិច្ចរបស់លោកនោះ គឺថាគាត់បានឆ្លើយនៅក្នុងម៉ោង ១៣:៥៧ នាទី "នេះគឺជាអ្វីដែលយើងបានឃើញប្រភពជាច្រើន ដែលយើងបានទៅប្រទេសនោះ ហើយយើងអនុញ្ញាតឱ្យរដ្ឋាភិបាលនោះលើកឡើង និងយើងមិនបាននិយាយជាមួយនឹងរដ្ឋាភិបាល ហើយយើងមិនអាចនិយាយជាមួយនឹងអ្នកផ្សេងទៀតដែលយើងគួរតែនិយាយ។ ខ្ញុំមិនឯកភាពទៅលើចំណុចទាំងអស់នេះទេ ដូចដែលលោកបានជ្រាប"។ លោក ឌុងម៉ាន ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំដកស្រង់ចំណុចដែលវែង ក៏ប៉ុន្តែខ្ញុំសូមផ្តល់ឱកាសឱ្យលោកប្រតិកម្មទៅនឹងសក្ខីកម្ម និងការរិះគន់របស់ អេលីហ្សាបេត បេកយ័រ ពាក់ព័ន្ធទៅនឹងអត្ថបទមួយច្បាប់ ដូចដែលលោកបានសរសេរនៅក្នុងកាសែតញូវយ៉កថាមស៍នេះ។

**ឆ៖** តើខ្ញុំគួរតែឆ្លើយយ៉ាងម៉េច គឺគ្មាននរណាគេរិះគន់ខ្ញុំទេ។ ខ្ញុំសរសេរអ្វីដែលខ្ញុំបានឃើញ។ ខ្ញុំសរសេរសាមញ្ញនូវអត្ថបទកាសែតសាមញ្ញធម្មតា ការដែលប្រជាជនគេសង្ស័យ ហើយខ្ញុំព្យាយាមរកព័ត៌មាននេះដោយខ្លួនឯងផ្ទាល់។ ខ្ញុំសួរនូវអ្វីដែលខ្ញុំបានឃើញតែប៉ុណ្ណោះ។ ខ្ញុំខឹងណាស់នៅពេលដែលគេនិយាយថា ខ្ញុំយោងប្រភពតែមួយនោះ គឺថាមិនដឹងគេចង់បានន័យយ៉ាងម៉េចទៅលើចំណុចហ្នឹង។

**ស៖** ខ្ញុំមិនយល់ដែរលោក ឌុងម៉ាន នេះជាចម្លើយរបស់ អេលីហ្សាបេត បេកយ័រ។ ខ្ញុំសូមសង្ខេបតែមួយប្រយោគសរុបមកវិញ។ ការរិះគន់របស់លោកស្រី អេលីហ្សាបេត បេកយ័រ គឺគាត់លើកឡើងរិះគន់ថា លោកមិនធ្លាប់បានមកឃើញប្រទេសកម្ពុជាពីមុនមកនោះទេ ហើយលោកមិនអាចមានលទ្ធភាពធ្វើការប្រៀបធៀបនូវអ្វីដែលកើតនៅប្រទេសកម្ពុជា នាពេលដែលលោកមកទស្សនកិច្ច និងអ្វីដែលកើតឡើងមុនពេលនោះឡើយ។ តើលោកប្រតិកម្មយ៉ាងម៉េចដែរលើចំណុចនេះ?

[០៨:៥៧:៤៤]

**ផ៖** ខ្ញុំអត់ចាប់សំណួរអត់បាន លោកមេធាវី។

**ស៖** ខ្ញុំសូមអធ្យាស្រ័យ ខ្ញុំសួរសំណួរឡើងវិញ។ វាហាក់ដូចជាបង្ហាញថា អេលីហ្សាបេក បេកឃ័រ បានរិះគន់លោកនៅក្នុងតុលាការនេះជាចំហថា លោកនេះមិនដែលធ្លាប់បានមកឃើញប្រទេសកម្ពុជាមុនពេលដែលលោកមកទស្សនកិច្ចនៅក្នុងឆ្នាំ១៩៧៨នោះទេ។ ហេតុដូច្នេះហើយ លោកមិនអាចមានលទ្ធភាពធ្វើការប្រៀបធៀបអំពីស្ថានភាពពិត និងស្ថានភាព សុខភាពរបស់ប្រជាជនកម្ពុជានោះទេ។ ដូចដែលលោកស្រី អេលីហ្សាបេត បេកឃ័រ គាត់ធ្លាប់មកកម្ពុជាមុនដែលឆ្នាំដែលលោកមកទស្សនកិច្ច។

**ផ៖** គាត់ អេលីហ្សាបេត បេកឃ័រ មកប្រទេសកម្ពុជាច្រើនជាង ហើយយូរជាងខ្ញុំ។ ដូច្នេះហើយ គាត់អាចមានទស្សនៈវិស័យច្រើនជាងខ្ញុំ។ ខ្ញុំមានបទពិសោធន៍ពីរតែប៉ុណ្ណោះ នៅក្នុងប្រទេសកម្ពុជា -- បីមិនមែនពីរទេ។ ទី១ គឺគេចាប់ខ្លួនខ្ញុំ ហើយគេគំរាមខ្ញុំឆ្នាំ៧៨ ហើយមកទស្សនកិច្ចម្តងទៀតឃើញខ្លួនឯងផ្ទាល់តែម្តង។ នេះបីដងបទពិសោធន៍របស់ខ្ញុំ។ នៅក្នុងបទពិសោធន៍នីមួយៗ ខ្ញុំសរសេរនូវអ្វីដែលខ្ញុំបានឃើញ អ្វីដែលខ្ញុំបានឆ្លងកាត់តែប៉ុណ្ណោះ។

**ស៖** តើរបាយការណ៍របស់លោកនៅក្នុងឆ្នាំ១៩៧៩នោះ តើវាជារបាយការណ៍មួយ វាវិជ្ជមាន ឬក៏ជារបាយការណ៍មួយដែលលោក មិនមែនជារបាយការណ៍រិះគន់ទេ គឺជារបាយការណ៍ដែលលោកបានឃើញ នៅក្រោយពេលដែលលោកបានមកទស្សនកិច្ច?

[០៨:៥៩:៤១]

**ផ៖** ជាការពិតដូច្នោះមែន។ អ្វីដែលខ្ញុំបានអានតាំងពីនោះមក ហើយនិងប្រភពទាំងឡាយដែលខ្ញុំប្រឹក្សានោះ។ ខ្ញុំគិតថាវាមានប្រល័យពូជសាសន៍មែន នៅក្នុងរបបប៉ុល ពត។ ដូច្នេះ ខ្ញុំនឹងមិនសរសេរអត្ថបទនោះទេ ប្រសិនបើដឹងអំពីហេតុការណ៍នេះ។

**ស៖** បាទ លោកយោងទៅលើរបាយការណ៍លោក ៧៩ ឬយ៉ាងម៉េច? បាទ ខ្ញុំគិតថាប្រហែលជាយើងត្រូវការសម្រាកលោក ឌុដម៉ាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអរគុណលោក ឌុដម៉ាន ឥឡូវនេះ ដល់ពេលសម្រាកហើយ។ យើងសម្រាក១០នាទីចាប់ពីពេលនេះទៅណាលោក ឌុដម៉ាន។ ដប់នាទីទៀតជួបគ្នា។

បាទ ឥឡូវនេះដល់ពេលសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក១០នាទី រហូតដល់ម៉ោងប្រាំបួន

ដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ សម្រាប់ម៉ោងនៅកម្ពុជា។

លោក ឌុងម៉ាន សម្រាក១០នាទី ហើយ១០នាទីទៀតជួបគ្នា។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង០៩:០១ នាទី ដល់ម៉ោង០៩:១១ នាទី)*

[០៩:១១:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ឌុងម៉ាន។

សូមអញ្ជើញលោក!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរសាជាថ្មីម្តងទៀតលោក ឌុងម៉ាន។

**លោក រីឆាដ ឌុងម៉ាន៖**

បាទ ជម្រាបសួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសុំងាកចេញពីឆ្នាំ១៩៧០ ប៉ុន្តែខ្ញុំមកនិយាយអំពីឆ្នាំ៧៨ ដែលលោកមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ។ យើងខ្ញុំទាំងអស់គ្នាបានអានរបាយការណ៍របស់លោកហើយ។ វាច្រើនឆ្នាំមកហើយ ប៉ុន្តែតើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា បទពិសោធន៍របស់លោកនេះយ៉ាងដូចម្តេចដែរ ក្នុងពេលលោកមកធ្វើទស្សនកិច្ចនៅក្នុងឆ្នាំ១៩៧៨?

**លោក រីឆាដ ឌុងម៉ាន៖**

**ឆ៖** ខ្ញុំតាមសំណួរលោកអត់ទាន់។ ខ្ញុំអត់យល់សំណួរ។

**ស៖** លោក ឌុងម៉ាន សំណួរខ្ញុំនេះ តើនៅពេលនេះ មកដល់ថ្ងៃនេះ តាមរយៈដំណើរទស្សនកិច្ច

របស់លោកនេះ លោកចាំយ៉ាងម៉េចដែរ? ហើយខ្ញុំបានជម្រាបថា ខ្ញុំបានអានរបាយការណ៍របស់លោកទាំងអស់គ្នាហើយ ប៉ុន្តែឥឡូវនេះ តើលោកអាចជម្រាបជូនតុលាការបានថាលោកចងចាំអ្វីខ្លះពីដំណើរទស្សនកិច្ចរបស់លោកនៅឆ្នាំ១៩៧៨?

[០៩:១៣:៥០]

**ឆ៖** ខ្ញុំចាំគេគំរាមខ្ញុំ។ ខ្ញុំចាំថាខ្ញុំបានធ្វើដំណើរទស្សនកិច្ចពិនិត្យមើលទីក្រុងភ្នំពេញ និងនៅទូទាំងប្រទេសផងដែរ ហើយការរៀបរាប់ដំណើរទស្សនកិច្ចហ្នឹង ពេលហ្នឹងខ្ញុំបានឃើញនៅពេលនោះ ខ្ញុំបានឃើញអ្វីៗនៅក្នុងឆ្នាំ១៩៨០ ដែលខ្ញុំសរសេរនោះគឺថា ខ្ញុំសរសេរតាមអ្វីដែលខ្ញុំបានឃើញនៅក្នុងឆ្នាំ៧៨។ តាមពិតទៅ គឺថាមានពីរផ្នែកតាមការចងចាំរបស់ខ្ញុំក្នុងឆ្នាំ៧៨ គឺទី១ ដំណើរទស្សនកិច្ចនោះដែលខ្ញុំ -- ខ្ញុំមិនពេញចិត្តទេទី១ គឺដំណើរទស្សនកិច្ចទី១។ តែដំណើរទស្សនកិច្ចមួយទៀត ខ្ញុំទទួលបានការគំរាមកំហែង ក្រោយពីខ្ញុំបានជួបជាមួយនឹង ប៉ុល ពត ហើយក្រោយមកខ្ញុំចាំថាវាជាបទពិសោធន៍គួរឲ្យរន្ធត់។

**ស៖** លោក ឌុដម៉ាន ខ្ញុំសូមសួរសំណួរខ្លះទៅលោក ទៅនឹងការវាយប្រហារមកលើ ម៉ាល់ខូម ខាដវែល។ នៅពេលនោះ -- ឥឡូវនេះ ខ្ញុំសូមសួរទៅលើដំណើរទស្សនកិច្ចរបស់លោក។ លោកបាននិយាយថា មានបញ្ហាដែលលោកមិនពេញចិត្តទេ។ ហើយនៅក្នុង -- ប៉ុន្តែក្នុងរបាយការណ៍របស់លោកនោះ ខ្ញុំឃើញថាលោកបាននិយាយថា លោកមានលទ្ធភាពប្រមូលផ្ដុំព័ត៌មានបានយ៉ាងច្រើន ហើយលោកមានឱកាសយ៉ាងច្រើនធ្វើការកត់សម្គាល់បានយ៉ាងពេញលេញ។ ក្រោយរយៈពេលដ៏ច្រើនឆ្នាំនេះ តើលោកអាចបំភ្លឺ តើលោកមានន័យថាម៉េចដែលថាលោកមានលទ្ធភាពប្រមូលព័ត៌មានសំខាន់ៗបានជាច្រើន ហើយក៏លោកមានឱកាសយ៉ាងច្រើន ដើម្បីធ្វើការកត់សម្គាល់បានយ៉ាងពេញលេញ។ សូមលោកជម្រាបជូនតុលាការផង។

[០៩:១៦:៣២]

**ឆ៖** ខ្ញុំនឹកឃើញរឿងហ្នឹង លោកនិយាយថា "ខ្ញុំបានសរសេរថា ខ្ញុំមានឱកាសប្រមូលព័ត៌មានបានយ៉ាងពេញលេញ" លោកសួរខ្ញុំថាអ៊ីចឹង?

**ស៖** បាទ ត្រូវហើយ ខ្ញុំអានរបាយការណ៍ឆ្នាំ១៩៧៩ របស់លោក គឺថាលោកមានលទ្ធភាពប្រមូលផ្ដុំព័ត៌មាន និងមានឱកាសពេញលេញ ដើម្បីធ្វើការកត់សម្គាល់។ អ៊ីចឹងសំណួររបស់ខ្ញុំថា ឥឡូវនេះ មកដល់ពេលនេះសូមលោកពន្យល់ឲ្យបានទូលំទូលាយលើចំណុចនេះបន្តិចបានទេ?

**ធ៖** ខ្ញុំអត់ចាំទេលោក នឹកមិនឃើញ។ អ្វីដែលខ្ញុំចង់និយាយនុ៎ង ហើយព័ត៌មានដែលខ្ញុំបានទទួល គឺខ្ញុំ -- ពេលនុ៎ងគឺខ្ញុំសរសេរអ្វីដែលខ្ញុំអាចប្រមូលព័ត៌មានបាន ប៉ុន្តែពេលនេះ ខ្ញុំនឹកមិនឃើញថាតើខ្ញុំមានលទ្ធភាពនោះ ទៅទទួលព័ត៌មានបានពីណាៗ នឹកអត់ឃើញ។

**ស៖** លោក ឌុដម៉ាន--

**ធ៖** *(គ្មានការបកប្រែ)*

**ស៖** *(គ្មានការបកប្រែ)*

**ធ៖** ខ្ញុំអត់ចាំៗ របាយការណ៍ហ្នឹងទេ។ បើសិនណាជាលោកចង់ ខ្ញុំសុំព្រីនវាចេញសិនលោកដើម្បីយកមកមើល។ ខ្ញុំមាននៅលើស្រ្គីននេះ តែខ្ញុំអានអត់ដាច់ទេ ខ្ញុំមើលអត់ឃើញទេ។

**ស៖** តើវាត្រូវទេ បើខ្ញុំនិយាយថា អ៊ីចេះ។ ដែលថាលោកមិនមាន -- មិនបានអានរបាយការណ៍ ១៩៧៩ របស់លោកទេ គឺមិនបានអានឡើងវិញទេ។ តើត្រឹមត្រូវទេ បើខ្ញុំនិយាយអ៊ីចឹង?

**ធ៖** ខ្ញុំអត់បានអានច្រើនឆ្នាំណាស់លោក។ ហើយខ្ញុំអត់ចាំ មិនចាំអត្ថបទហ្នឹងនិយាយពីអីផង។

**ស៖** លោក ឌុដម៉ាន ប្រហែលជាយើងកំពុងតែច្របូកច្របល់ក្នុងបញ្ហាពីរ។ ខ្ញុំបានចាប់ផ្តើមសួរលោកអំពីអត្ថបទ អំពីញូវយ៉កថាមស៍ -- នៅក្នុងញូវយ៉ក -- កាសែតញូវយ៉កថាមស៍។ ឥឡូវនេះ ខ្ញុំសូមយោងទៅរបាយការណ៍ដែលលោកបានសរសេរនៅខែមករា ១៩៧៩។

**ធ៖** ខ្ញុំៗឃើញលោកមេធាវីនៅលើអេក្រង់ ប៉ុន្តែខ្ញុំអត់បានអានឡើងវិញផង ហើយខ្ញុំអត់ចាំទេ បើអត់បានអានឡើងវិញផង។ ខ្ញុំមិនដឹងចាំថា ខ្ញុំសរសេរស្អីខ្លះផង។

[០៩:១៩:៥៩]

**ស៖** ខ្ញុំយល់។ បើលោកមិនយល់ទាស់ទេ ខ្ញុំសូមអានកថាខណ្ឌជាក់លាក់មួយចំនួន ពីអត្ថបទរបស់លោក ដើម្បីជួយរំឭកដល់ការចងចាំរបស់លោក។ លោកប្រធានគឺឯកសារ E3/3290, ERN ជាភាសាអង់គ្លេស 0041927។ លោក ឌុដម៉ាន នេះគឺនៅត្រង់ទំព័រទី២ ខ្ញុំសូមអានឲ្យលោកស្តាប់តែម្តង គឺអត្ថបទរបស់លោកសរសេរដូចតទៅ៖ "នៅពេល ខ្ញុំធ្វើដំណើរទស្សនកិច្ច យើងមានការសន្ទនាគ្នាហ្នឹង គឺថាមានកម្រិតណាស់"។ លោក ឌុដម៉ាន លោកឃើញត្រង់ចំណុចនេះទេ?

ខ្ញុំសូមអានឲ្យលោកស្តាប់ម្តងទៀត។ នៅទំព័រទី៣ "នៅពេល ខ្ញុំធ្វើដំណើរទស្សនកិច្ចមកទីនេះ គឺថាសន្ទនារបស់យើងមានភាពតឹងរ៉ឹងណាស់ជាមួយនឹងប្រជាជនកម្ពុជាជាសាមញ្ញទូទៅនោះ។ ហើយយើងមិនមានលទ្ធភាពនិយាយជាមួយអ្នកណាបានក្រៅតែមេដឹកនាំកំពូលពីរនាក់ហ្នឹង។ មានឱកាសពេញ

លេញដើម្បីធ្វើការ -- ខ្ញុំទៅធ្វើទស្សនកិច្ច ១៩ខេត្ត”។ នៅទីនេះ លោកប្រើពាក្យថា “មានឱកាសពេញលេញដើម្បីធ្វើការកត់សម្គាល់”។ តើលោកចាំទេថាលោកបានសរសេរឃ្លានេះ ហើយនៅពេលនេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ហេតុអ្វីបានជាលោកសរសេរឃ្លានេះ?

**ឆ៖** ពិតហើយ។ ខ្ញុំនឹកឃើញ យើងមិនអាចនិយាយទៅកាន់អ្នកណាបានទេ ដំណើរទស្សនកិច្ចរបស់យើងគឺថាមានការរឹតត្បិតមែនទែន។ ប៉ុន្តែខ្ញុំបើកភ្នែកមើលអ្វីៗទាំងអស់ដែលខ្ញុំអាចមើលឃើញបាននៅក្នុងដំណើរទស្សនកិច្ចនេះ។ ហើយខ្ញុំសរសេរអ្វីដែលខ្ញុំបានឃើញ។ ខ្ញុំមិនដឹងថាត្រូវនិយាយអ្វីទៀតដើម្បីឆ្លើយទៅនឹងសំណួររបស់លោកទេ។

**សៈ** អ្វីដែលខ្ញុំចង់សួរ ក្រៅពីការរឹតបន្តឹងដំណើរទស្សនកិច្ច តើលោកមានពេលមើលឃើញអ្វីៗឲ្យបានគ្រប់ -- ឲ្យបានពេញលេញ ដើម្បីសរសេររបាយការណ៍ឲ្យបានពេញលេញអំពីស្ថានភាព នៅក្នុងកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[០៩:២៣:២៧]

**ឆ៖** ខ្ញុំមិនដឹងថា ខ្ញុំបានសរសេរថា មានរបាយការណ៍ពេញលេញអំពីអ្វីដែលបានកើតឡើងនាពេលនោះទេ។ បញ្ហាទាំងអស់នោះគឺវាមានការរឹតបន្តឹង។ ខ្ញុំសរសេរអ្វីដែលខ្ញុំបានឃើញ ខ្ញុំបានដឹង ខ្ញុំសរសេរអ្វីៗដែលខ្ញុំបានដឹង បានឃើញ។

**សៈ** ហើយទៅមុខហ្នឹងបន្តិច នៅក្នុងរបាយការណ៍របស់លោកហ្នឹង ខ្ញុំសូមដកស្រង់ម្តងទៀតដើម្បីជួយរំឭកដល់ការចងចាំរបស់លោក។ “ក្រៅពីការរឹតបន្តឹងអំពីសកម្មភាពរបស់យើង គឺថាយើងមានលទ្ធភាពប្រមូលផ្តុំព័ត៌មានសំខាន់ៗអំពីកម្ពុជាថ្មីជាលើកដំបូង ចាប់តាំងពីជោគជ័យរបស់កុម្មុយនីស្តជាង៤ឆ្នាំកន្លងមកនេះ។ ខ្ញុំចាប់អារម្មណ៍ពាក្យថាព័ត៌មានសំខាន់ៗលេចធ្លោ”។ ឥឡូវនេះ តើលោកនឹកឃើញទេ តើលោកមានន័យយ៉ាងម៉េចដែរចំពោះពាក្យថា “យើងមានឱកាសពេញលេញ លេចធ្លោ” នេះ?

**ឆ៖** ពិតមែន ខ្ញុំនឹកមិនឃើញទេ។ ខ្ញុំមិនដឹងថា ខ្ញុំប្រើពាក្យហ្នឹង សំដៅយ៉ាងម៉េចទេ។

**សៈ** លោក ឌុដម៉ាន តើវាអាចយល់បានទេ ដែលថាលោកមានឱកាស ស្អែកនោះ គឺថាសូមឲ្យលោកមើលអានរបាយការណ៍ ១៩៧៩របស់លោកឡើងវិញ ដើម្បីរំឭកការចងចាំរបស់លោក។ ដើម្បីឲ្យខ្ញុំអាចសួរលោក ឬក៏ភាគីដទៃទៀតសួរលោកបាន តើបើសំណួមពរអ៊ីចឹងធ្វើបានទេលោក?

**ឆ៖** ខ្ញុំឥឡូវនេះ ខ្ញុំមើល កំពុងតែមើលតែម្តង។

[០៩:២៦:៣៩]

**ស៖** លោក ឌុដម៉ាន អត្ថបទនេះ គឺជាអត្ថបទមួយវែងណាស់ ខ្ញុំសូមកាត់លោកបន្តិចហើយ លោកមិនអានរបាយការណ៍នេះឲ្យបានពេញលេញ ក្នុងរយៈពេលមួយដែលយើងមានកម្រិត និងមានរយៈពេលខ្លីអីចឹងទេ។ ខ្ញុំសូមអានសម្រង់ខ្លីទេ ហើយចាំសួរលោកមើល៍ ថាតើវាជួយរំឭកដល់ការចងចាំរបស់លោកដែរទេ។ អង់គ្លេសត្រង់ទំព័រ៤, ERN គឺ00419208។ កថាខណ្ឌទី១ ដែលនិយាយថា សូមដកស្រង់៖ “នៅពេលជាមួយគ្នានេះដែរ ស្ថានភាពរស់នៅមិន -- មានការរីកចម្រើន ជាពិសេសសម្រាប់ប្រជាជនកម្ពុជាភាគច្រើនដូចដែលរបបនេះបានអះអាង”។ នេះគឺជាសម្រង់ចេញពីរបាយការណ៍របស់លោក។ លោក ឌុដម៉ាន តើលោកអាចពន្យល់ឲ្យវែងឆ្ងាយជាងនេះបន្តិចទេ តាមការចងចាំរបស់លោក ត្រង់ឃ្លានេះ?

**ឆ៖** ហ្នឹងគឺមានការវិវត្តន៍មួយចំនួន។ ខ្ញុំសរសេរអ្វីដែលខ្ញុំបានឃើញ។

**ស៖** ប្រហែលជាខ្ញុំសូមតាំងសំណួររបៀបផ្សេងវិញ។ តើលោកចាំទេ ថានៅពេលហ្នឹង លោកសរសេររបាយការណ៍របស់លោកបានរបៀបហ្នឹងបានដោយរបៀបណា? តើលោកមានប្រើកូនសៀវភៅកត់ត្រាដែលលោកបានកត់ត្រានៅក្នុងពេលធ្វើទស្សនកិច្ចដែរទេ?

**ឆ៖** បាទ។

**ស៖** លោក ឌុដម៉ាន លោកនៅតែមានកំណត់ត្រាដោយដៃរបស់លោកទេ ពីដំណើរទស្សនកិច្ចហ្នឹង?

**ឆ៖** ខ្ញុំស្តាប់សំណួរអត់ទាន់ទេ លោក។

**ស៖** តើលោកនៅតែមានកូនសៀវភៅកត់ត្រារបស់លោកនៅក្នុងដៃទេ សព្វថ្ងៃហ្នឹង?

**ឆ៖** ខ្ញុំអត់មានទេ។

[០៩:២៩:១២]

**ស៖** តើលោកមិនដឹងថាលោកមិនមាន ឬក៏លោកមានទេ?

**ឆ៖** ខ្ញុំអត់មានទេ។

**ស៖** លោក ឌុដម៉ាន លោកចាំទេ ពេលហ្នឹង លោកមានបានថតរូបទេ ពេលមកធ្វើទស្សនកិច្ចហ្នឹង?

**ឆ៖** ខ្ញុំចាំថា ខ្ញុំបានថត ប៉ុន្តែដឹងថតអ្វីខ្លះទេ។

**ស៖** ខ្ញុំចាំច្បាស់ណាស់ ថាលោកបានរបាយការណ៍របស់លោកសម្រាប់ខាង *សិទល្វ* នោះ។ តើ

លោកចាំទេ?

**ឆ៖** ខ្ញុំអត់យល់ទេ លោកមេធាវី។

**ស៖** លោកសរសេររបាយការណ៍របស់លោកសម្រាប់ទស្សនាវដ្តី *សិនលូ* តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកចាំទេ តើមានការពិភាក្សាជាមួយនឹងអ្នកនិពន្ធនាយករបស់លោកទេ ឬក៏ជាមួយអ្នកណាម្នាក់ទេ មុននឹងកំណត់យករបាយការណ៍ជាចុងក្រោយ?

**ឆ៖** ខ្ញុំអត់ៗចាំទេ កាលនុ៎ង ខ្ញុំបានផ្ញើរបាយការណ៍ហ្នឹងតាមរយៈតេឡេក្រាមទេ។ គេផ្ញើតាមតេឡេក្រាមពីប្រទេសកម្ពុជា។ ខ្ញុំមិនចាំទេ លោកមេធាវីថា ខ្ញុំសរសេរនៅត្រង់ចំណុចណាទេ។ កាលនុ៎ងខ្ញុំត្រឡប់មកវ៉ាស៊ីនតោន ហើយសរសេរឲ្យកាសែត *សេនឡួដ ផុសឌីស្ពេត (តាមការបកប្រែ)*។ គឺខ្ញុំដឹងថាខ្ញុំបានសរសេរអ៊ីចឹង។

[០៩:៣១:៤១]

**ស៖** ខ្ញុំដឹងហើយថាវារយៈពេលយូរណាស់ហើយលោក ឌុដម៉ាន។ ខ្ញុំសុំទោសផងដែលខ្ញុំសួរលម្អិតពេក រយៈពេលវាយូរមកហើយ ហើយវាពិបាកនឹងចងចាំផង។ ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចឲ្យបានលម្អិតអំពីរបាយការណ៍របស់លោក។ ប៉ុន្តែលោកចង់ -- លោកចាំយ៉ាងម៉េចដែរ លោកចាំបានអ្វីខ្លះដែរពីរាត្រីមួយនោះ យប់មួយនោះ ដែលលោកទាំងបីនាក់ត្រូវបានឆ្មាំកាំភ្លើងបាញ់ប្រហារចូលមក? លោកចាំអ្វីខ្លះអំពីរឿងហ្នឹង?

**ឆ៖** ខ្ញុំចាំ ខ្ញុំឮសូរសំឡេងផ្ទុះ។ ខ្ញុំបានឆ្លងទៅជាន់ទី២ ទៅបន្ទប់នៅជាន់ទី២ ហើយខ្ញុំបានដើរកាត់បន្ទប់ធំមួយដើម្បីទៅឆ្ពោះទៅកាន់បន្ទប់ ម៉ាល់ខូម ដើម្បីនិយាយជាមួយគាត់ហ្នឹងថា តើអ្វីដែលកំពុងតែកើតឡើងនេះ។ ហើយយើងទាំងអស់គ្នានៅ -- យើងអត់ដឹងថាមានអ្វីកើតឡើង យើងសម្រេចថានឹងស្នាក់នៅក្នុងបន្ទប់។ ហើយក្រោយមក បុរសក្មេង -- យុវជនក្មេងម្នាក់នោះ មានអាវុធចេញមកតាមពីជាន់ខាងក្រោយ នៅពេលនោះ គាត់ភ្ជង់កាំភ្លើងខ្លីដាក់មកតម្រង់មកខ្ញុំ ហើយបាញ់សំដៅខ្ញុំ ប៉ុន្តែបាញ់ខុសហើយខ្ញុំក៏ ខ្ញុំគេចចេញពីមាត់ទ្វារបន្តិច ហើយក្រោយ -- ដើម្បីពួន។ ហើយក្រោយមកក៏មានគ្រាប់បាញ់ទម្លុះតាមមាត់ទ្វារ ហើយខ្ញុំព្យាយាមឡើងទៅលើ ចូលក្រោមគ្រែ ប៉ុន្តែវាទាបពេក ចូលអត់ៗចុះ។

ហើយប្រហែលជាពីរម៉ោងក្រោយមក ខ្ញុំឮសូរសំឡេងគ្រាប់កាំភ្លើងពីរគ្រាប់ទៀត។ ហ្នឹងរយៈពេលពីរម៉ោងក្រោយពីសំឡេងផ្ទុះពីមុនហើយ។ ហើយមាន គឺមានសូរសំឡួងគោះទ្វារ ម៉ាល់ខូម ហើយ

មានអ្នកការទូតៗកម្ពុជា គឺឈ្មោះ ជួន ប្រសិទ្ធិ មានវត្តមាននៅកន្លែងខ្ញុំស្នាក់នៅ។ ហើយគាត់និយាយថា លោកស្រី បេកយ័រ គឺមិនអ្វីទេ។ ហើយគាត់សួរខ្ញុំថា "លោកឯងអត់អីទេអ្ហេស?" ហើយគាត់ប្រាប់ថា លោកស្រី បេកយ័រ ក៏មិនជាបញ្ហាអ្វីដែរ ប៉ុន្តែលោក ខាដវែល ត្រូវបានគេបាញ់ស្លាប់បាត់ទៅហើយ។ ហើយក្រោយមក អ្នកការទូតកម្ពុជាហ្នឹង ហៅខ្ញុំឲ្យទៅពិនិត្យមើលសាកសព។ ខ្ញុំបានពិនិត្យមើលសាកសព ខ្ញុំឃើញគាត់ដេកស្លាប់ស្លុកស្លឹងមានរបួសនៅត្រង់ទ្រូង។

[០៩:៣៥:១៨]

គាត់នៅក្នុងបន្ទប់របស់គាត់ទេ ប៉ុន្តែវានៅតាមផ្លូវចូលមកទ្វាររបស់គាត់ ខ្ញុំមើលឃើញថា មើលទៅដូចជាបុរសក្មេងដដែល ដែលគំរាមកំហែងខ្ញុំ ហើយបុរសក្មេងហ្នឹងក៏ស្លាប់ដែរ ហើយកំពុងដេកនៅក្នុងថ្លុកឈាមដែរ។ លោកស្រី បេកយ័រ ហើយនិងខ្ញុំនោះ នៅក្នុងថ្ងៃដដែលហ្នឹង យើងក៏បានចាកចេញពីផ្ទះភ្ញៀវហ្នឹងចាកចេញទៅចិន និងសំដៅទៅសហរដ្ឋអាមេរិក ហើយយើងពេលហ្នឹងគឺគេបានយកសាកសពរបស់ ខាដវែល ហ្នឹងទៅជាមួយនឹងយើងដែរ។

**ស៖** សូមអរគុណលោក ឌុដម៉ាន ដែលលោកបានរៀបរាប់លម្អិតរឿងនេះ។ លោកចាំទេថា លោកមានការសន្ទនាជាមួយ ជួន ប្រសិទ្ធិ ថាហេតុអ្វី ហើយនិងសួរអំពីមូលហេតុនៃការបាញ់ប្រហារមកលើលោកទាំងបីនាក់នេះទេ?

**ឆ៖** គឺថាខ្ញុំមាន យើងមាននិយាយគ្នាច្រើន ប៉ុន្តែយើងមិនបានដឹងអំពីរឿងនេះទេ។

**ស៖** ដើម្បីជួយដល់ការចងចាំរបស់លោកបន្ថែមទៀតនោះ នៅក្នុងរបាយការណ៍របស់លោកក្នុងឆ្នាំ១៩៧៩ហ្នឹង លោកបានហៅថា សូមដកស្រង់ថាជា "ការវាយប្រហារដោយពួកភេរវករមកលើលោក"។ ហេតុអ្វីក៏លោកពាក្យថា "ជាការវាយប្រហារបែបភេរវកម្ម"? ម៉េចក៏លោកប្រើពាក្យថាអ៊ីចឹង?

**ឆ៖** ខ្ញុំអត់បានប្រើពាក្យហ្នឹងទេ។ ខ្ញុំអត់ចាំទេ។

**ស៖** តើលោកអាចចាំដោយរបៀបណាមួយដែលថា តើអ្នកអាចជាអ្នកទទួលខុសត្រូវចំពោះការវាយប្រហារនេះទេ?

**ឆ៖** ខ្ញុំឮសួរ ខ្ញុំឮហេតុផលច្រើនណាស់ ប៉ុន្តែយោបល់ផ្ទាល់ខ្លួនខ្ញុំមិនអាចនិយាយបានទេ។

**ស៖** ហេតុផលដែលលោកឮផ្សេងៗគឺ លោកឮនៅពេលនុំងតែម្តង ពេលក្រោយបាញ់ប្រហារហ្នឹង ឬក៏ក្រោយមកទេ?

**ឆ៖** ខ្ញុំឮសួរតាំងពីពេលហ្នឹងមកនោះ។ ខ្ញុំឮតាំងពីពេលហ្នឹង ឮមូលហេតុច្រើនណាស់ ឮមូលហេតុខុសៗគ្នា។

**ស៖** លោកមានចាំទេថា មានហេតុផលណាមួយ ទ្រឹស្ដីណាមួយដែលអាចអូសទាញលោកបានទេ? ឬក៏ថាវាយូរពេកហើយ លោកមិនអាចបកស្រាយបាន?

**ឆ៖** តាមពិតទៅខ្ញុំនឹកមិនឃើញ មិនដឹងថាហេតុផលមួយណាដែលគួរឲ្យខ្ញុំជឿជាក់បានទេ។

**ស៖** ខ្ញុំសុំអានសម្រង់ចេញពីសៀវភៅមួយក្បាល ប្រហែលជាលោកមិនបានអានសៀវភៅនេះទេ ប៉ុន្តែខ្ញុំសុំបង្ហាញលោក ហើយសួរមើលថា តើលោកប្រតិកម្មយ៉ាងដូចម្ដេចដែរ ចំពោះសៀវភៅនេះ?

លោកប្រធាននេះគឺជាឯកសារ E3/4202, ERN អង់គ្លេស 00757538, បារាំង 00844451, ខ្មែរ 00858363។ លោក ឌុដម៉ាន នេះគឺជាសម្រង់ចេញពីសៀវភៅមួយក្បាលដែលសរសេរដោយ ថេត សម្បត្តិ។ ហើយ ថេត សម្បត្តិ គាត់សរសេរអំពីប្រតិកម្មរបស់ ប៉ុល ពត និង នួន ជា។ គឺប្រតិកម្មរបស់ ប៉ុល ពត និងនួន ជា ពាក់ព័ន្ធទៅនឹងព្រឹត្តការណ៍បាញ់ប្រហារនេះ។

ឥឡូវនេះ ខ្ញុំសុំដកស្រង់ចេញពីសៀវភៅរបស់គាត់ហ្នឹងហើយសួរមើលថា តើលោកយល់យ៉ាងម៉េចដែរ ហើយមានប្រតិកម្មយ៉ាងម៉េចដែរ? តើខ្ញុំអាចសួរលោកលើសៀវភៅនេះបានទេ?

[០៩:៤០:០៣]

**ឆ៖** បាទ បាន។

**ស៖** នៅចុងបញ្ចប់នៅឆ្នាំ១៩៧៨ ប៉ុល ពត គាត់សម្រេចថា ចង់ឲ្យខ្មែរក្រហមអញ្ជើញអ្នកកាសែតបីនាក់ឲ្យមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ គឺអ្នកកាសែតឆ្វេយឆ្លង -- អ្នកសារព័ត៌មានអន្តរជាតិ រីឆាដ ឌុដម៉ាន ជាមួយនឹង អេលីហ្សាបេត បេកយ័រ ហើយនិងមកធ្វើទស្សនកិច្ចក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងចំនួន១០ថ្ងៃនៅក្រុងភ្នំពេញ។ នៅយប់បន្ទាប់ពីបទសម្ភាសន៍ជាមួយ ប៉ុល ពត រួចមក ម៉ាល់ខូម ខាដវែល ត្រូវបានបាញ់សម្លាប់នៅកណ្ដាលអធ្រាត្រ នៅយប់នោះ។ ក្រោយមក អេលីហ្សាបេត បេកយ័រ បានសរសេរកំណត់ហេតុនៅក្នុងសៀវភៅរបស់ខ្លួន "នៅពេលសង្គ្រាមរលត់ទៅ" ដែលសំណេរនោះមានន័យថា "ឃាតកម្មលើ ម៉ាល់ខូម ខាដវែល គឺជាការប៉ុនប៉ងធ្វើឲ្យខូចកេរ្តិ៍ឈ្មោះរបស់របបខ្មែរក្រហម"។

"នួន ជា បាននិយាយថា ប៉ុល ពត បានមកដាស់គាត់នៅវេលាម៉ោងបីរំលងអធ្រាត្រនៅយប់នោះដើម្បីប្រាប់ថា អំពីឃាតកម្មលើលោក ខតវែល។ នៅពេលនោះ នួន ជា មានការរន្ធត់តក់ស្លុត

យ៉ាងខ្លាំង។ នៅពេលនោះស្ថានភាពតឹងតែង ប្រឈមមុខជាមួយវៀតណាម ហើយ ប៉ុល ពត បារម្ភថា រឿងនេះគឺកលល្បិចដើម្បីបំផ្លិចបំផ្លាញកេរ្តិ៍ឈ្មោះរបស់កម្ពុជា។ ប៉ុល ពត បាននិយាយថា រឿងនេះកើតឡើងដោយសារតែគ្មានការប្រុងប្រយ័ត្ន ប៉ុន្តែគាត់បាននិយាយថា នរណាជាអ្នក -- មិនបាននិយាយថា នរណាខុសទេ។ យើងពិតជាមានការសោកស្ដាយចំពោះរឿងនេះ ពីព្រោះយើងជាអ្នកអញ្ជើញឲ្យពួកគាត់មកប្រទេសយើង ដូច្នេះយើងត្រូវតែការពារពួកគាត់។ យើងមិនឆ្កួតដល់ថ្នាក់បាញ់សម្លាប់ជនបរទេសទេ។ ខ្ញុំយល់ឃើញថា នេះគឺជាកលល្បិចរបស់ខ្មាំង ដើម្បីបង្ខូចកេរ្តិ៍ឈ្មោះយើង"។ បញ្ចប់ការដកស្រង់។ បើរំឭកអំពីព្រឹត្តិការណ៍ហ្នឹង ហើយនិងអំពីមូលហេតុផ្សេងៗ តើលោកមានមតិយោបល់យ៉ាងម៉េចដែរ ទៅលើសម្រង់ដែលខ្ញុំអានជូនលោកក្នុងសៀវភៅនេះ?

[០៩:៤២:១១]

**ឆ៖** គឺថាមានការពន្យល់ច្រើន។ ខ្ញុំមិនដឹងវាពិត ឬក៏អត់ទេ។

**ស៖** ត្រឹមត្រូវហើយលោក ឌុដម៉ាន។ ក៏ប៉ុន្តែតាមរបៀបណាមួយនោះ តើវាជួយរំឭកដល់ការសន្ទនារបស់លោកនៅពេលនោះជាមួយនឹង ជួន ប្រសិទ្ធិ ទេ។ វាជួយរំឭកដល់រឿងហ្នឹងទេ?

**ឆ៖** ជាមួយអ្នកណា?

**ស៖** ជាមួយនឹងមន្ត្រីក្រសួងការបរទេសឈ្មោះ ជួន ប្រសិទ្ធិ។ តើសម្រង់នេះវាជួយរំឭកដល់ការសន្ទនារបស់លោកជាមួយនឹង ជួន ប្រសិទ្ធិ ទេ?

**ឆ៖** ខ្ញុំអត់ចាំការសន្ទនារបស់ខ្ញុំជាមួយ ជួន ប្រសិទ្ធិ ដែលជាមន្ត្រីក្រសួងការបរទេសនោះទេ។

**ស៖** សូមអរគុណលោក ឌុដម៉ាន។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីដំណើរទស្សនកិច្ចរបស់លោកពីរបីថ្ងៃដំបូង។ គឺកិច្ចសម្ភាសន៍របស់លោកទាំងពីរដែលលោកបានធ្វើឡើង។ គឺ អេលីហ្សាបេត បេកយ័រ និងលោក តែពីរនាក់នេះជាមួយនឹង ប៉ុល ពត។ តើលោកនៅចាំអំពីការសន្ទនារវាង អេលីហ្សាបេត បេកយ័រ លោក ហើយនិង ប៉ុល ពត ទេ?

**ឆ៖** ខ្ញុំចាំ ប៉ុន្តែខ្ញុំឲ្យនឹកឃើញការសន្ទនាឲ្យពេញលេញ នឹកមិនឃើញទេ។

**ស៖** តើលោកយល់ -- តើវាជារបៀបម៉េច វាជារបៀបហៅថា ជារបៀបបង្រៀន ឬក៏ជារបៀបសុន្ទរកថា?

**ឆ៖** ជារបៀបបង្រៀន។

**ស៖** លោកចាំអ្វីជាក់លាក់ទេ? អំពីៗការសន្ទនានេះ លោកចាំអ្វី -- ការបង្រៀននេះគឺជាក់លាក់ទេ?

**ឆ៖** បាទ ចាំ។

**ស៖** តើលោកចាំអ្វីខ្លះដែរ?

**ឆ៖** ខ្ញុំចាំថា ប៉ុល ពត និយាយម្តងហើយម្តងទៀតថា គឺវៀតណាមហ្នឹងគឺចង់ឈ្លានពានកម្ពុជា ហើយគាត់ ប៉ុល ពត និយាយដដែលៗក្នុងរឿងហ្នឹង បើខ្ញុំចាំមិនច្រឡំទេ ពេលហ្នឹងប៉ុល ពត និយាយថា "ជាមួយនឹងការជួយជ្រោមជ្រែងពីសហរដ្ឋអាមេរិក គឺថាកម្ពុជាអាចនឹងៗរុញច្រានវៀតណាមឲ្យថតទៅវិញបាន"។

[០៩:៤៤:៤៥]

**ស៖** លោកមានចាំអ្វីក្រៅពីហ្នឹងទៀតទេ? ចាំថា ប៉ុល ពត និយាយមកលោក មកកាន់លោក អំពីទស្សនវិស័យ ការយល់ឃើញ -- តើវៀតណាមមានគោលបំណងម៉េចដែរ? គោលបំណងនៃការឈ្លានពានមកលើកម្ពុជា មានគោលបំណងស្អីដែរទេ?

**ឆ៖** ខ្ញុំអត់ចាំទេ។ គាត់បាននិយាយ អំពីការឈ្លានពាន អំពីការលុកលុយ។

**ស៖** លោកមានចាំអ្វីលម្អិតក្រៅពីការលុកលុយនេះទេ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ប៉ុល ពត ហ្នឹង?

**ឆ៖** ខ្ញុំអត់ចាំទេ។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំមានសំណើមួយ មិនមែនសម្រាប់តែពេលនេះទេ គឺថាអង្គជំនុំជម្រះគួរអនុញ្ញាតឲ្យខ្ញុំសួរឲ្យលោក ឌុដម៉ាន ស្តាប់សម្រង់ពីកិច្ចសម្ភាសន៍នេះ តែ៧នាទីទេ សម្រង់មានរយៈពេល៧នាទីចាក់ឲ្យគាត់ស្តាប់។ ហើយធ្វើបែបនេះ ខ្ញុំសង្ឃឹមថានឹងរំឭកដល់ការចងចាំរបស់គាត់។ សម្រង់ពាក់ព័ន្ធហ្នឹង យើងបានសរសេរវាចូលមកហើយ ខ្ញុំយល់ឃើញថាសំណើសុំនេះហាក់យឺតពេលបន្តិច ក៏ប៉ុន្តែយើងបានដាក់ចូលទៅក្នុង *អ៊ីនធើហ្វេស* ហើយ ជូនដំណឹងទៅដល់ភាគី ទៅដល់អង្គជំនុំជម្រះហើយ។ បើអនុញ្ញាតយ៉ាងដូច្នេះ គឺថាពេលវេលាខ្ញុំវាអាចលើសពីម៉ោងដប់បន្តិច ដូច្នេះតើអង្គជំនុំជម្រះសម្រេចយ៉ាងម៉េចដែរចំពោះសំណើសុំនេះ?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់សូមសួរលោកមេធាវី ប្រសិនបើចាក់ឥឡូវ ពេលហ្នឹងទៅ ថាតើលើសម៉ោងដប់ ហ្នឹងប៉ុន្មាននាទី រួមទាំងសំណួររបស់លោកមេធាវី?

**លោក វ៉ិចទ័រ កូប៉េ៖**

អត្ថបទដែលចាក់ហ្នឹងគឺប្រហែលជាប្រាំបួន ដប់នាទី។ ដូច្នេះវាចាក់ចប់ ត្រឹមម៉ោងដប់ ប្រាំនាទី ហើយបន្ទាប់មកនឹងមានសំណួរបន្ថែមទៀត។ ដូច្នេះ បាទ វាជាការល្អប្រសិនជាយើងចាក់នៅថ្ងៃស្អែកទៅ។ ផលប្រយោជន៍ចាក់ថ្ងៃស្អែកនោះគឺថា ខ្ញុំក៏អាចបញ្ជូនលោកចៅក្រមនូវចំណុចដកស្រង់ផ្ទាល់ចេញពីអត្ថបទដែលចាក់ ឬក៏គេហៅថា ប្រតិចារឹក ជាកំណត់ត្រាប្រតិចារឹកដែលខ្ញុំផ្តល់ជូនចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើវាម៉ោងហ្នឹង វាស្ថិតនៅក្នុងម៉ោងដែលលោកចែករំលែកជាមួយនឹងមេធាវីការពារក្តីផ្សេងទៀត ឬយ៉ាងម៉េចដែរ?

[០៩:៤៩:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសូមសួរបញ្ជាក់ពីខាងមេធាវីខាងនេះសិន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកស្រីចៅក្រម ហ្វេនស៍ និងលោកប្រធាន ខ្ញុំត្រូវការប្រហែលជាតែ៤០នាទីទេ ដើម្បីសួរលោក ឌុងម៉ាន។ ដូច្នេះ ប្រសិនបើខ្ញុំយល់មិនច្រឡំទេ យើងមាន២ម៉ោង ២០នាទីជារួមសម្រាប់ក្រុមយើងទាំងពីរ -- សុំទោសគឺ ២ម៉ោង៤០នាទី សម្រាប់ក្រុមមេធាវីការពារក្តីទាំងពីរ។ អ៊ីចឹងបើខាង កូប៉េ គាត់ត្រូវការ ២ម៉ោង អ៊ីចឹងខ្ញុំត្រូវការតែ ៤០នាទីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមលើកឡើងចំណុចមួយចំនួន យើងខ្ញុំបានទទួលបានប្រតិចារឹកដែលមេធាវីការពារក្តីលើកឡើងអម្បាញ់មិញនេះ។ សំណួរដែលខ្ញុំចង់សុំសួរនោះ តើខ្សែអាត់នោះ ជាភាសាខ្មែរ ឬក៏យ៉ាងម៉េច?

ហើយយើងអាចចាក់ជាភាសាខ្មែរតែម្ដងទៅ ហើយឱ្យសាក្សីហ្នឹង គាត់ស្ដាប់ទាំងភាសាខ្មែរ និងការបកប្រែទៅជាភាសាបរទេស រួមពេលជាមួយគ្នា។ ហើយខ្ញុំទទួលបានប្រតិចារឹកហើយ ហើយវាជាការល្អ ដូចដែលបានលើកឡើងអ៊ីចឹង មិនគួរចាក់ផ្សាយនៅពេលនេះទេ ខ្សែអាត់ហ្នឹង។

[០៩:៥០:៥៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្សែអាត់ហ្នឹង គឺសំឡេងរបស់ប៉ុល ពត ជាភាសាខ្មែរ ហើយបកប្រែផ្ទាល់ជាភាសាអង់គ្លេស ដោយ ជួន ប្រសិទ្ធិ តាមខ្ញុំស្មាន។ យើងអាចចាក់តែម្ដងនៅពេលនេះក៏បានដែរ យើងមានទាំងប្រតិចារឹកជាភាសាបារាំងផងដែរ ហើយខ្ញុំបានស្ដាប់កាលពីម្សិលមិញ វាវាងវែងផងដែរ ហើយប្រតិចារឹកហ្នឹងក៏មិនមែនថាត្រូវទាំងស្រុងនោះផងដែរ។ ដើម្បីជាប្រយោជន៍ដល់តុលាការ និងលោក ឌុដម៉ាន នោះ យើងគួរតែស្ដាប់ពាក្យពេចន៍ចេញនុំង ផ្ទាល់ៗតែម្ដងទៅ។ ហើយពេលខ្លះទៅក៏វាពិបាកស្ដាប់ដែរ ខ្សែអាត់ហ្នឹង។

នៅពេលនេះ ខ្ញុំស្នើអ៊ីចេះ លោកប្រធាន។ ខ្ញុំសូមសួរសំណួរចុងក្រោយរបស់ខ្ញុំសិន ហើយវាជាការប្រសើរ យើងគួរតែចាក់នៅថ្ងៃស្អែកទៅ ខ្សែអាត់ប្រតិចារឹកនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមអធ្យាស្រ័យលោក ឌុដម៉ាន ដែលផ្អាករយៈពេលខ្លីអម្បាញ់មិញនេះ។ លោកបានស្ដាប់ឮអម្បាញ់មិញហើយ។ យើងខ្ញុំនឹងចាក់ខ្សែអាត់ដែលលោក ជាមួយនឹង អេលីហ្សាបេត បេកយ័រ ជាមួយនឹង ប៉ុល ពត យើងនឹងចាក់នៅថ្ងៃស្អែក។ នៅពេលនេះ ខ្ញុំសូមសួរសំណួរមួយចំនួន ទាក់ទងទៅនឹងការរៀបចំនូវទស្សនកិច្ចរបស់លោកនាពេលនោះ។ តើលោកនៅចាំទេ តើលោកបានរៀបចំទស្សនកិច្ចមកប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៨ ខែធ្នូនោះ ដោយរបៀបណាដែរ?

[០៩:៥២:៥០]

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំទទួលសំណួរអត់បាន លោកមេធាវី។

**ស៖** សំណួរដែលខ្ញុំចង់សួរ គឺតើលោកចាំទេ ថាលោកខ្លួនឯង លោករៀបចំទស្សនកិច្ចហ្នឹងដោយរបៀបម៉េច? តើលោកបានធ្វើខ្លះមុនពេលដែលមកប្រទេសកម្ពុជា? តើលោកបានជួបនិយាយជាមួយនឹងមន្ត្រីនៅក្រសួងការបរទេសដែរឬទេ? ឬក៏លោកមានការរៀបចំយ៉ាងម៉េចដែរ នៅមុនពេល

ដែលមកទស្សនកិច្ចនោះ?

**ឆ៖** ខ្ញុំមិនចាំលម្អិតនោះទេ ក៏ប៉ុន្តែខ្ញុំបាននិយាយជាមួយនឹងអ្នកជំនាញជាច្រើន។ តើខ្ញុំគួរតែមកដើម្បីរកអីនៅប្រទេសកម្ពុជា។

**ស៖** តើលោកនៅចាំទេ មុនពេលមកទស្សនកិច្ច លោកបានឮអំពីការគេធ្វើសវនាការអំពីភាពតានតឹងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមដែរឬទេ?

[០៩:៥៣:៥៧]

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** តើលោកនៅចាំថា លោកធ្លាប់បាននិយាយជាមួយនឹងក្រសួងការបរទេស មន្ត្រីនៅទីនុំងជាមួយ -- លោកធ្លាប់បាននិយាយជាមួយ ដូក្លាស ផាយ *(Douglas Pike)* ទេ ដែលគាត់ធ្វើការនៅក្រសួងបរទេស?

**ឆ៖** ខ្ញុំស្គាល់គាត់ ដូក្លាស ផាយ។ ខ្ញុំចាំថាបានធ្លាប់បាននិយាយជាមួយគាត់នៅពេលនោះ។

**ស៖** តើលោកចាំទេ ថាលោកបាននិយាយជាមួយគាត់នោះ អំពីភាពតានតឹងរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។

**ស៖** តើលោកចាំថា លោកបានអានឯកសារមួយឈ្មោះថា "សៀវភៅខ្មៅ" ដែរឬទេ មុនពេលដែលលោកមកប្រទេសកម្ពុជា?

[០៩:៥៥:០៧]

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** ប្រសិនបើខ្ញុំសូមរំឭកលោក គឺឯកសារសៀវភៅខ្មៅនេះ គឺចេញដោយក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងនោះសរសេរថា សរសេរអំពីហេតុផលនៃការឈ្លានពានរបស់ប្រទេសវៀតណាម។ តើលោកនៅចាំទេ?

**ឆ៖** ខ្ញុំអត់អាចជួយឲ្យខ្ញុំចាំបាននោះទេ ខ្ញុំអត់ចាំទេ។

**ស៖** តើលោកចាំទេ មុនពេលដែលលោកមកទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៨ ប្រទេសវៀតណាមបានចុះកិច្ចព្រមព្រៀងយោធាជាមួយនឹងសហភាពសូវៀត។

**ឆ៖** ខ្ញុំអត់ចាំទេ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក ឌុងម៉ាន ដែលបានឆ្លើយតបទៅនឹងសំណួរទាំងឡាយរបស់ខ្ញុំ ហើយសូមអរគុណដែលលោកអត់ធ្មត់ចំពោះសំណួរដែលខ្ញុំសូម -- ដែលបានសួរលោក។ សូមអរគុណច្រើនលោក ឌុងម៉ាន។

[០៩:៥៦:៤១]

**ប្រធានអង្គជំនុំ៖**

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ -- នៅថ្ងៃនេះ ដល់ពេលត្រូវឈប់សម្រាកហើយ។ អង្គជំនុំជម្រះ ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី រីឆាដ ឌុងម៉ាន។ សូមភាគី --

បាទ ម៉ោងប្រាំបីព្រឹកណ៎ា សូមភាគីនិងជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាកំណត់នេះ។ ហើយអង្គជំនុំជម្រះ សូមអរគុណលោក រីឆាត ឌុងម៉ាន។ ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សីនៅពេលនេះ នៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបីព្រឹក។ ហើយនៅពេលនេះលោកអាចសម្រាកបានហើយ។

ហើយអង្គជំនុំជម្រះ សូមអរគុណផងដែរ ចំពោះលោកមេធាវី ចេសិន បារែត និងមេធាវី - មេធាវី ថូដ ឡូវែល ដែលជាជំនួយការមេធាវី ចេសិន បារែត អង្គជំនុំជម្រះអញ្ជើញលោកទាំងពីរមកបន្តចូលរួមអង្គុយក្បែរសាក្សី រីឆាដ ឌុងម៉ាន ក្នុងអំឡុងពេលសាក្សីផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបីព្រឹកទៅ ម៉ោងនៅកម្ពុជា។

បាទអង្គជំនុំជម្រះ បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបី។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង០៩:៥៨នាទី)*